# កម្ពុជសុរិយា


ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ បោះពុម្ពផ្សាយ អំពីពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកអក្សរសាស្ត្រៈ ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម, បណ្ឌិត នៅ ពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកដំណឹងសាសនាៈ ព្រះគ្រូបញ្ញាលិក្ខិត កៅ-ស៊ឹម អ្នកគ្រូតព្រៈ សិស្ស នៅសាលាបាលីជាន់ខ្ពស់


## បញ្ជីរឿង


| | | ទំព័រ |
|---|---|---|
| *ផ្នែកអក្សរសាស្ត្រ* | | |
| នាកញ៉ាៈទេពពិទូរ-គ្រីសេម | ប្រវត្តិស្ដេចទឹកស្ដេចភ្លើង | ៦៦៣ |
| " " " | វណ្ណគតិ នារាយណ៍ ទសាវតារ (តមក) | ៦៧៤ |
| ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម | ព្រះរាជក្រឹត្យ ក្រមចៅហ្វាយស្រុក (តមក) | ៦៨៣ |
| " " " | សេចក្ដីសង្ខេបអំពីគោលៈផ្សេងៗ នៃពង្សាវតារខ្មែរ (តមកនឹងចប់) | ៦៩៣ |
| ឃុនខត្តមប្រីជា ជាប-ពិន | អធិប្បាយសុភាសិតខ្មែរ (តមក) | ៧០០ |
| *ផ្នែកសាសនា* | | |
| ព្រះអាចារ្យ ជាំង-ទាត់ | អរិយសច្ចជាពុទ្ធភាសិត (តមកនឹងចប់) | ៧០៥ |



ឆ្នាំទី ១៧ – លេខ ១១ ខែណូវែម្ប៊ី ១៩៤៥ – តំលៃជាវ: ១ ឆ្នាំ ១៥ រៀល ។


*No. 11*

# ប្រវត្តិស្តេចទឹកស្តេចភ្លើង

## ឧកញ៉ា ទេពពិទូរ ក្រសេម រៀបរៀង

ពួកដែលព្រះមហាក្សត្រខ្មែរ ទ្រង់តាំងឲ្យធ្វើជាស្តេចគ្រប់គ្រង មនុស្សព្រៃនៅក្នុងស្រុកព្រៃ ហើយត្រូវឡើងស្តេចខ្មែរ ហៅថា ស្តេចទឹក ស្តេចភ្លើង ។

រឿងស្តេចទឹកស្តេចភ្លើង ជារឿងនៅក្នុងជំពូកដែលត្រូវសុំបាលាយទៅខ្លះ ដូចយ៉ាងរឿងឯទៀត ៗ ដែលគេទៃតធ្វើនេះជាប្រែមកហើយ, ការរៀបរៀងក្នុងគ្រានេះ ដោយការស្រាយស្រុបសួរតាមចាស់ទុំជាច្រើននាក់ នៅក្រុងភ្នំពេញនេះខ្លះ នៅខេត្តសំបុក (ក្រចេះ) ឯណោះខ្លះ និងតាមស្រាយព្រះរាជក្រឹត្យ[១] ១ ច្បាប់របស់ព្រះបាទសម្តេច ព្រះស្រីសុរិយោពណ៌ ដែលទ្រង់ឲ្យរៀបរៀងទុកមកខ្លះ ទើបសម្រេចបានជារូបរឿងដូចមានតទៅនេះ ។

## ហេតុដែលកើតមានស្តេចទឹកស្តេចភ្លើង

ទំនៀមគ្រប់គ្រងប្រទេសអំពីដើមរបស់ខ្មែរ មានព្រះរាជាម្ចាស់ផែនដីជាប្រមុខនៅក្នុងព្រះនគរ មានសេនាបតីតាំង ៦ ឬតាំង ៥ នៅក្នុង

---

១ ព្រះរាជក្រឹត្យច្បាប់នេះ ព្រះបាទសម្តេចព្រះស្រីសុរិយោពណ៌ទ្រង់ឲ្យរៀបរៀងទុកក្នុងឆ្នាំ មហាសករាជ ១៥២៣ (ច.ស. ៩៦០) គេប្រទះឃើញនៅខេត្តសំបុក (ក្រចេះ) លោក ប៉ុះ ពៅ លេខាធិការពុទ្ធសាសនបណ្ឌិត្យបានចម្លងមក ហើយឧកញ៉ាទេពពិទូរ សេម ចម្លងទុកនៅពុទ្ធសាសនបណ្ឌិត្យ ខ. ក្បាលលេខ ៩៩ - ១៤ ។

គ្រងជាអ្នកសម្រេចកិច្ចការតំណាងព្រះអង្គ, តាមជនបទស្រុកក្រៅមាន ចៅហ្វាយស្រុក ចៅហ្វាយខេត្ត រហូតដល់ស្ដេចត្រាញ់ជាទីបំផុត ជាអ្នកគ្រប់គ្រង ដូចមានពោលហើយក្នុងរឿងព្រះរាជពិធីស្នានចតុរង្គ-សេនាឯណោះ តែទោះគ្រប់គ្រងចំពោះតែបន្ទុកអ្នករួមជាតិផងគ្នា, នៅមានមនុស្សច្រើនពួកផងទៀត គឺពួកព្នង ចារាយ សម្រែ រដែ កួយ ពារ ជាដើម, សិងតាត់ជាចំពួក «មនុស្សព្រៃ» មនុស្សពួកនេះជាអ្នកកាប់គួនកូនផុះអារ្យធម៌ ហើយមិនស្របចូលចិត្តនឹងសេចក្ដី រឿងចាស់ពីបុ-ការបស់ខ្លួន តាំងចិត្ត ចុះសោតកំរើដំរិះស្រលាញ់ស ដូច្នេះទើបបានគៀសខ្លួនទៅរកស្រែយលើទៅតែជាយដែនដងព្រៃ តាមជាយចុងព្រះរាជាណា-ចក្រកម្ពុជា រកស៊ីចិញ្ចឹមជីវិតទៅតាមចំណង់ចិត្តខ្លួន ឥតមានព្រះរាជាឬរាជការគ្រប់គ្រងផ្ទាល់ ដូចអារ្យជាតិឯទៀត ។

រាជការខ្មែរគ្រប់ៗណាសម័យក៏បានក្រឡេកមើលទៅពួកនេះដែរ តែប្រៀបលជា ឃើញថា ខឹងគៀកកោយឲ្យមកនៅក្រោមអំណាចដោយត្រង់ដូចហានជាតិខ្មែរផងគ្នាពុំបាន តែនឹងបណ្ដោយឲ្យទៅតាមចំណង់ក៏ពុំស្រួល ទើបបានគេរៀបចំសមត្ថនុយក្រី ដោយតាំងមនុស្សក្នុងពួកនោះឲ្យជាមេគ្រប់គ្រងគ្នាឯង ហៅថាស្ដេចទឹក ស្ដេចភ្លើង ដើម្បីគេក្រសេចក្ដីសុខក្នុងដែនដងព្រៃ នឹងកំណត់ជាអ្នកនៅក្នុងជាតិខ្មែរ, ដូចជានឹងមានអធិប្បាយដោយខាងក្រោម :

# វង្សក្សត្រស្ដេចទឹកស្ដេចភ្លើង

ពួកមនុស្សព្រៃនោះមានច្រើនពួក អាស្រ័យនៅក្នុងកម្ពុជរដ្ឋតាំងពីបុរាណកាលមកដូចមានពោលហើយក៏ក្នុងពួកមនុស្សព្រៃទាំងនោះ ជាតិជាអ្វីដែលត្រូវបានតាំងជាស្ដេចទឹកស្ដេចភ្លើង។ តាមដែលចាស់ទុំទាំងឡាយដំណាលតៗមកដរាបដល់សព្វថ្ងៃនេះថា ជាតិព្នង(១), តែតាមសេចក្ដីកត់ហេតុរបស់លោក ញូន-សៀង ដែលក្រសួងពុទ្ធសាសនបណ្ឌិត្យចាត់ឲ្យទៅស៊ើបសួរយកការដល់ស្រុកសំបុក កាលក្នុងខែវិច្ឆិកាឆ្នាំ ១៩៦៤ នោះថា ជាតិជ្រាយ តែថា ជាតិជ្រាយនោះជាជាតិមួយក្នុងពួកព្នង ក្នុងព្រះរាជក្រឹត្យព្រះបាទស្រីសុរិយោពណ៌ មិនបានចេញឈ្មោះថាជាជាតិអ្វី គ្រាន់តែថា ស្ដេចទឹកស្ដេចភ្លើង ជាម្ចាស់លើអស់ស្រុករដ្ឋជ្រាយ-ព្នង ។

ទីលំនៅស្ដេចទឹកស្ដេចភ្លើងនៅតំបន់ណា ? ក្នុងជាន់ដើមជាខាងតាំងនៅតំបន់ណា ខ្លះ ឬមួយតាំងនៅតែមួយកន្លែងតាំងពីដំបូងដរាបមកដល់សម័យនេះ។ ខនេះគេមិនអាចដឹងបានជាប្រាកដទេ តាមក្នុងព្រះរាជក្រឹត្យរបស់ព្រះបាទស្រីសុរិយោពណ៌ថា "នៅលើកំពូលភ្នំ" តែភ្នំនោះឈ្មោះអ្វី នៅក្នុងតំបន់ណា មិនបានប្រាប់ឲ្យច្បាស់ តាមដែលលោក ម៉ាន់-នាង

១ មានអ្នកខ្លះថាពួកទ្រុងឬរហោង តែកាលស៊ើបសួរយកការទៅក៏ត្រូវឡប់ផាយប្រាកដទៅវិញ ។

ព្រមព្រួខ្លាសនបណ្ឌិតបានទៅស៊ើបសួរអ្នកស្រុកសំបុក ក្នុងខែការិល ឆ្នាំ ១៩៤៤ បានទៅលើភ្នំ ១ ឈ្មោះម៉ែនប្រាកដ [1] នៅជាប់ខ្នារភ្នំបាតជាស់ នឹងកំពង់ផុន ក្នុងស្រុកព្នង ។ ស្តេចទឹកស្តេចភ្លើងគាត់ស្រែយ ចំកុង ត្រូវលើភ្នំតូចភ្នំនោះ ឥតមានផ្ទះសំបែងទេ មនុស្សរស់នៅទៀតទេ ។

ប្រវត្តិតាំងជាស្តេចទឹកស្តេចភ្លើង មានតាំងពីកាលណា ? បានស្រាវជ្រាវគន្ធពលខ្លះមកហើយ តាំងពីខាងខ្មែរ តាំងពីខាងព្នង តែមិនបានប្រទះប្រវត្តិពិតប្រាកដសោះ ខាងខ្មែរតាមដែលបានស៊ើបសួរអ្នកចាស់ព្រឹទ្ធាចារ្យ តាំងឡាយគេបានតែត្រឹមថា មានមកពីបុរាណកាលជាអន្លើហើយ បំណែកខាងព្នង តាមដែលគេបានស៊ើបសួរព្នងខ្លះ ដែលនៅក្នុងស្រុកនោះ ក៏មិនអាចឆ្លើយបានច្បាស់ ព្រោះព្នងគ្មានអក្សរកត់ត្រាទុកមកទេ តាមដែលប្រាកដក្នុងព្រះរាជក្រឹត្យ ព្រះបាទព្រះស្រីសុរិយោពណ៌គឺថា មានមកពីបុរាណកាល សមដូចពាក្យថា "នាកាលដំណាលពីបុរាណរៀង ១ មកតោះ ៣ ឆ្នាំក៏ឲ្យឡើងមកសួរមង្គល" គឺថាព្រះមហាក្សត្រអំពីដើម មុនរជ្ជកាលព្រះបាទព្រះស្រីសុរិយោពណ៌ឡើងរាជនោះ ធ្លាប់តែងតាំងស្តេចទឹកស្តេចភ្លើងមកហើយ កំណត់ក្នុង ៣ ឆ្នាំ ឲ្យរាជទូតឡើងទៅសួរសុខទុក្ខម្ដង ។ សេចក្តីនេះក៏នៅតែមិនច្បាស់

[1] បើនឹង ហៅឈ្មោះតាមហេតុដែលស្តេចទឹកស្តេចភ្លើងអង្គុយនៅ គួរហៅថា "ភ្នំស្តេចទឹកស្តេចភ្លើង" ។

ហាសជួបគ្នា តាំងលំដាប់រាជ្យក្សត្រតាំងអំពីដំបូង ដរាបមកដល់សម័យនេះ មានប៉ុន្មានអង្គ នាមដូចម្តេចខ្លះ ក៏គ្មានប្រទះប្រាកដដល់បច្ចុប្បន្នសោះ តាំងពីគ្មានអ្នកដឹងស្គាល់បានសូម្បីមួយអង្គឡើយ ការស្រាវជ្រាវរបស់គេ ស្តេចទឹកស្តេចភ្លើងកន្លងមកនេះ ទោះបីគេនាំគ្នាថា មិនសូវបានផលបរិបូណ៌តាមដែលត្រូវការឡើយ តែការបំប្រួញទៅបានសេចក្តីថា ស្តេចទឹកស្តេចភ្លើងជាអ្នកជាតិ មានមកតាំងអំពីព្រេងនាយតែប៉ុណ្ណោះ ។

## របៀបពិធីតែងតាំងស្តេចទឹកស្តេចភ្លើង

ការដែលនឹងតាំងជាស្តេចទឹកស្តេចភ្លើង ក៏មានជាពិធី ១ ដែរ ប៉ុន្តែតាមដែលស៊ើបសួរអ្នកចាស់ព្រឹទ្ធាចារ្យខ្លះ ក៏គង់តែមិនបានសេចក្តីល្អិតល្អសព្វគ្រប់ ព្រោះស្តេចទឹកស្តេចភ្លើងគេលើកលែងនិយមមកយូរហើយ តែនេះទោះជា កន្លងពេលដែលរៀបរៀងរឿងនេះបានខ្ញុំបាទស៊ើបសួរគេទៅបាន ឬក៏រឿងព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះស្រីសុរិយោពណ៌ និយាយពីរឿងតែងតាំងស្តេចទឹកស្តេចភ្លើង សឹងមានសេចក្តីល្អិតល្អ ល្មមដឹងរឿងរ៉ាវបាន ដោយច្បាស់លាស់តាមសេចក្តីទាំងចុងនៃព្រះរាជក្រឹត្យនោះថា មានការទាក់ទងមិនបានទៅមករកគ្នាជាយូរហើយ ព្រោះមានកន្ទល់ផ្លូវក្រៅ លុះមកដល់កន្លងរជ្ជកាលព្រះបាទសម្តេចព្រះស្រីសុរិយោពណ៌ ប្រហែលជាស្រុកទេសបានសុខត្រាណហើយ

ទើបទ្រង់រៀបចំស្ពានតាស្តេចទឹកស្តេចភ្លើង ឲ្យមានដូចដើមឡើងវិញ ដូចមានប្រាកដក្នុងព្រះរាជកំណត់នោះស្រាប់ ព្រះរាជកំណត់ដែលទាក់ទងដោយរឿងនេះ មាន ២ ច្បាប់ គឺ ១ ច្បាប់និយាយពីរឿងសាងវត្តសំបុកក្នុងខែត្រក្រចេះទុកជាទ្វារព្រះនគរ, ១ ច្បាប់ទៀតនិយាយពីរបៀបតាំងស្តេចទឹកស្តេចភ្លើង សឹងនៅរួមជាមួយគ្នា ដូចជានឹងនាំមកចុះតទៅនេះ:

## ច្បាប់និយាយពីសាងវត្តសំបុក

"សុភមស្តុ[១] បរមត្ថ កាលសម្ពលាដៃយាតិរេកបាន ១៨២៣ សកច្ចនក្សត្រ ទសកេជ មាឃមាសា សសិពក សាសុក្កមហោត្តិមហោឡា (៖) បវរកនុកុល កុល ពីព្រះរាជហារ័ទ ខៃព្រះបាទព្រះស្រីសារពេជ សម្តេចព្រះរាជឱង្ការ ព្រះស្រីសុគាទទិព្វពេជ បរមកជាធិកជ និមិត្តរបរេតដោដៃយ ត្រៃភូមកុជ វិសុទ្ធជនសាសន (៖) បរមត្ថ បឋមកត្ត[២] អគ្គកជាធិកជ បរមនាថ បរមបូពិត កិត្តហាទយោ[៣] ទសាភិមន្គល តំកលព្រះរាជហារ័យ ទ្រង់ព្រះសទ្ធាកើតជាព្រះអសំតារិកញ្ញាណ មានព្រះប័តិសោមនស្ស ទ្រង់ព្រះសទ្ធានឹងសាងក្រាលព្រះវិហារទៅឯស្រុកក្រៅលំនៅផនបទ កំណត់ព្រះរាជទានទុកជាព្រះកិត្តិព្រះសាស្នា ឲ្យកើតផលាអនិសង្ស ក្នុងកាលព្រះនគរ

---

១ សុភមស្តុ ។ ២ បរមេត្ថកត្ត ។ ៣ ធរិតហទយោ ។

ចម្រើនរុងស្រួលសម្រេចសព្វកាល នោះចៅព្រះឃ្លាំងសិរីសារពេជ សំគេប ព្រះរាជឱង្ការ ព្រះស្រីសុពារ បរមរាជាធិរាជ បរមនាថ បរមបពិត្រ អ្នកជាអម្ចាស់ ត្រាស់ប្រើព្រះមហាគោកជ ខ្ញុំកញ្ញាកាមាធិរាជ() យក ព្រះរាជទ្រព្យមកធ្វើស្អាងព្រះវិហារ ស្អាងព្រះវិ ស្អាងព្រះចេតី នៅ ស្រុកសំបុកនេះ ទុកជាគ្នាព្រះទេវតា បរស្រុកក្រុងកម្ពុជាធិបតី ស្រីឥន្ទបថ មហានគរ បវរពជនាទី លុះស្អាងស្រួចហើយ ទើបព្រះឃ្លាំង សិរីសារពេជ សូមទូលព្រះរាជឱង្ការ ព្រះស្រីសុពារ បរមរាជាធិរាជ បរមនាថ បរមបពិត្រ អ្នកជាអម្ចាស់ ត្រាស់ប្រើមហាគោកជ ខ្ញុំ កញ្ញាកាមាធិរាជ ឲ្យយកខ្ញុំម្នាក់ដែលកំសត់ទំនិញព្រះអង្គ ៤០ គ្រួ មកប្រោស........................................

ព្រះឃ្លាំងសិរីសារពេជ សំគេចព្រះរាជឱង្ការ ព្រះស្រីសុពារ បរមរាជាធិរាជ បរមនាថ បរមបពិត្រ អ្នកជាម្ចាស់ ត្រាស់ប្រើព្រះមហាគោកជ ខ្ញុំកញ្ញាកាមាធិរាជ យកមកប្រោសទុក ឲ្យរក្សាព្រះវិហារ រក្សា ព្រះចេតីយ នៅវត្តសំបុក ទុកជាគ្នាព្រះទេវតា បរស្រុកក្រុងកម្ពុជាធិបតី ស្រីឥន្ទបថ មហានគរនគរហោង ។

នោះទើបព្រះឃ្លាំងសិរីសារពេជ សំគេចព្រះរាជឱង្ការ ព្រះស្រីសុពារ បរមរាជាធិរាជ បរមនាថ បរមបពិត្រ តំរូវហាមឃាត់ ស.កម្ពុ[២]

---

១ ម្ចាស់ភព ។ ២ ម.ឃ កំពុង (ម្ចាស់ ...) ។

ផ្គុំព្រះនាមករ បរមេន្ទ្រពារសម្តេចព្រះអរិយវង្សាជានេះ ឲ្យហៅថាសម្តេច ព្រះនាគនេវរពោធិបញ្ញា មហាពោធិ សិរិសង្ឃបរិនាយកតិលកលោកា-ចារិយមហាសង្ឃរាជ បរមបពិត្រឲ្យក្រុង ៦០ គ្រួសារព្រះនគរ បវរ ស្រុកក្រុងកម្ពុជាធិបតី ស្រីឥន្ទបដ្ឋមហានគរ បវរកជាតិ នាមទេ-យោគព[1] សួស្តីសម្រិទ្ធិសព្វកាល ។

ឯនីងយកដើមកប (កាសី) នោះ បើចញ្ញាំម្ហូបមកក៏ ចញ្ញាំ គោក ស្តុក ហប លុង បានក្រុងចូលមកក៏ ចញ្ញាំសំពត់ចូលមកក៏ ឯ រនិកបមកសម្រាប់កងភាព គ្មានបានទៅទៅក្រោយស្រុកយក ; ឯគ្រឿ ងព្រៃព្រឹក្សបើង បានមកជាគ្រឿងយសម្រាប់ព្រះស្រីគ្រឿងនោះ បាន គ្រឿងអំពុកៈព្វាការធំ ប្រែភាគទន្ទេ រៀងទៅតល់ពាមកកុត បទទៅឯកើត ព្រៃព្រៃស្រុកនេ ស្រែស្រែ បទទៅឯត្បូងត្រើយត្រពាំងស្វា ; ឯព្រៃនោះ បានព្រៃកកកោះ ព្រៃខ្សាច់ ព្រៃអន្ទងបង្អាច ព្រៃកំពង់ ព្រៃ កកុក ; ឯៈបឹងបានបើងទេ បើងរុន បើងឈើតាម បើងសំបុក បើង កល្ពុរ បើងដើមព្រះ ; ឯព្រៃបានព្រៃធំ ព្រៃប្រហូត ព្រៃក្រសៀ ព្រៃតម្លៃង ស្រុកទាំងនេះបានមកជាគង្សព្រះស្រីគ្រឿង ។

លោកឲ្យចកញ្ញា ឪដ្ឋានគ្របើស្តុកលោះ គត់លើកាត់ផ្តៅ ប្រែ ស្វ៊ូបម្រុងកាកមព្រះវិហារកុំឲ្យខ្ទូចកាតព្រះសាស្នា ទោះអនាគតគង់លេទៅ

---

១ ជាភិរម្យភាព ។

ឯកែក ឲ្យសឹក ២ ហូពានជួយទំនុកបម្រុងក្នុងព្រះសាសនា ឲ្យជួយគេក្រុំ ឲ្យបាក់បែកខូចខាតគាពមនេះឡើយ ។

## (ព្រះរាជក្រឹត្យតាំងស្តេចទឹកស្តេចភ្លើង)

នេះច្បាប់ប្រដាប់នឹងតាំង (តាំង) ស្តេចទឹកស្តេចភ្លើងនោះ (គឺ) គីរណោល ២, ក្លួបលនាំគហាត្ថលកយត្ថាយ ២, ក្រប ២, សំពតហូលបប្ពូរគោមសខ្មៅក ២, ទុលេំទូង ២, ពូក ២, ខ្នល ២, ខ្នើយ ២, កន្ទេលពោសត្ត ២, កន្ទេលដប់គហត្ថ ២, ភាជន ២ សម្រាប់, គ្រឿងបាយ ២ សម្រាប់, គ្រឿងទឹក ២ សម្រាប់, ទោជាក្តក្រហម ២០, ស្ក ២ គូ ប៉ីមេក្លូន ២ គូ, ទាំងយូរកន្ទុង ២, ពានប្លាញជាវុង ២, ពានបាយ ១០០, ពានស្ល ១០០, ពានគៀប ១០០, ពានកន្ទោង ១០០ អម្បិលរវេះ ២, កែកកើរ្យ ៥០០, សម្ពរ ២០, ស្លឹកនឹងក្រាស ២ សម្រាប់, បន្ទាកធាក បន្ទាកពោះ ២ សម្រាប់, សំពត្តខៀវ ២ ប្រវែងហត្ថ ៥, អម្ពល ២០០, លុទ្ទន[1] ២ ចង្វន ត្រែ ២ ចង្វននេះសម្រាប់នឹងព្រះខ័នខ្សែព្រះរាក់, ឈ្នួតព្រែក្រហម ២ ប្រវែងហត្ថ ៥, អង្គាំត្រាប់ផ្ទុ ២០ ក្បាល, តែងស្ពាន ២, តែងបាន ២០០, កំរៀកត្រា ២, កន្ទៀតបន្ទោះ ២, ផ្គាក់ ២, ផ្ទុកក្រដាំស ២, ចំពៀងស្ពាន ២០០, សន្ទូច ២០០, ទូកក្រហម ២, ស្លា ១០ នាល, ស្លាផ្កា ១០ នាល, ថ្ម ១០ នាល សៃរកៀរ ២, ដប្ប ២, ទ្រ ២,

---

១ លំនេង ឬ លុទ្ទន ជាឈ្មោះសេះពំនាំមួយគ្នា ។

ប៉ីអ ២, ឯម្រាប់គ្រឿងគោក្រហម ២, សៀនគែប ២ កាក់លើតាក និមួយៗ ឯគ្រឿងស្លាគោគៈ ផ្លែមៀនហ៊ា ២, ប្រទាក ២, អកកំបុរ ២, គោគះមៀនហ៊ា ២ ។

បើអ្នកស្ដេចស្រុកក ១ ខ្ញុំគង់ព្រះជន្ម ១ នោះឲ្យប្រគាប់ប្រសាធ ហ្វើង តំរៀញ ១, តំរៀណ្ហាល ១, លុះទៅពញា ទេសអន្ទក់ ខ្ញុំចែកញ៉ា-ធិកពិការ ខ្ញុំទៅពញាធិកចរិយានាំប្រសាទឡើងទៅដល់ៈ

នេះច្បាប់ធីងតាមស្ដេចទឹកស្ដេចភ្លើង គើមលើឲ្យពញាធិកចរិយា ស្លូតបម្រើនពារ គេនមេងាភេតីម ទើបយកស្បៀគ្រឿងចន្ទាភោរបៀបជាជួរ ២ សង្ខាងហើយ ទើបអ្នកគ្រូស្លូតព្រះនាមនោះឲ្យប្រែពាក្យជាភាសាសាស្រ-គេ ទៅអគ្គីយនាកណ្ដាលជុំទុំមស្លូត ៣ តង ឯកាលទីងស្លូតបម្រើនពារ នោះ ឲ្យមានភ្លើងភ្លាតជុំមបុះមកខ្ញុំប្រគំមគោរពខ្ញុំសោស្សគេៈ

ព្រះរាជឧក្កាបរមសារសេន្ទបេរ ព្រះទំព្រមុកមនូលវិមលសោតម បរមទេតាសារសេរីបរមេត្តតិទ្យអាចិនៃត្រៃ នៃព្រះវាទសម្ដេចព្រះចៅពា-ផ្ទៃក្រុងកម្ពុជាធិបតី សិរីសិរីឧបថ កុរុស្តាជជាទី បរមនាថ បរមបពិត ព្រះចៅក្រុងអម្ចាស់ព្រះស្សលព្វ ចែកញាធិកពិការ ខ្ញុំទៅពញាធិក-ចរិយា ឲ្យទូលថា នាំព្រះរាជឧក្កា ខ្ញុំព្រះរាជបន្ទាភោរផង ចេញមក ដល់ស្រុកអាយុធ អាចុាំ ប្រសិទ្ធសំបើត នាម្ចាបម្រើនពារក្បាស្ដេចទឹក ស្ដេចភ្លើង - តម្កលកម្កើងហ្វើងសន្ទតមកឲ្យហៅថា ស្ដេចទឹកស្ដេចភ្លើង

ស្មឹមា រក្សាព្រះខាន់នៅលើកំពូលភ្នំ ផុតមប្រកដ្ឋជាអម្ចាស់លើផ្សស្រុក – រៃក ព្រាយ ពួន គ្នាគះគ្មានប្រះវណីអំពីបូកណារៀង ១ មក តែងនឹង កាន់តែងរក្សាការក្រងប្រយាតផ្ទាំព្រៃ សព្វរៃផង ឲ្យតិងជា តិងកាប ឲ្យគបនូវតែជះត្បះដែយសិទ្ធិឲ្យផ្សេញ ខេព្រាក អារក្ខផងរក្សាបរម៉ែន កាយុ. ឲ្យវៃងយឺនយូរបបូ ស្មើគថេរចិរកាលវិជ្ជាអៅយោង ។

(មាឥត)

# នារាយណ៍ ទសាវតារ

ឧកញ៉ាទេពពិទូ ក្រសេម រៀបរៀង (តមក)

គ្រប់ខួបឆ្នាំដែលធ្វើពិធី មហេសីទាំង ៣ ក៏ប្រសូតឱរស ព្រះវសិដ្ឋមុនីជាអ្នកថ្វាយព្រះនាម គឺឱរសកើតអំពីនាងកៅសល្យានាមជាព្រះរាម (ជាទីស្រឡាញ់) ជារដ្ឋទាយាទ, ឱរសកើតអំពីនាងសុមិត្រានាមជាព្រះលក្ស្មណ៍ (ល្អព្រម) និងព្រះសត្រុឃ្ន (អ្នកវិនាសសត្រូវ) ឱរសកើតអំពីនាងកៃកេយី នាមជាភរត (អ្នកគាំពារ) ។

កាលព្រះរាមមានព្រះជន្មបាន ១០ ឆ្នាំ ព្រះវិស្វាមិត្រមកទូលព្រះបាទទសរថថា មានយក្ស ២ រូបគឺមារីចនិងសុពាហុ រះតែមករំអុក ទើបសូមព្រះរាមទៅកម្រាប មានកំណត់ ១០ ថ្ងៃ ព្រះបាទទសរថមិនអាចទទឹងទទឹងទាស់ក៏បានព្រមឲ្យទៅព្រះលក្ស្មណ៍តាមស្ដេចទៅផង កាលមកដល់ឆ្នេរទន្លេសរយុ ព្រះវិស្វាមិត្របង្ហាញមន្តវិជ្ជាការឲ្យការពារខ្លួនជូនទ្វេមក ដល់ដែនដីព្រៃដែលជាស្រុកធំមួយអំពីដើមឈ្មោះ មល័យករូស ដីជាទីលំនៅនាងតាឌកានិងនាងសុក្ខាបុក នាងទាំងពីរនេះកាចក្រៃលែង ចាប់មនុស្សស៊ីអស់ទាំងខេត្ត ស្រុកទេសទើបទៅជាព្រៃជ្រះ ព្រះរាមបានបង្រាបនាងយក្ខិនីទាំងពីរបង់ ព្រះវិស្វាមិត្រមានអំណរណាស់ ទើបថ្វាយ

អាវុធៈផ្សេងៗ ជាបំណាច់ទឹងបង្រៀនមន្តវិជ្ជាការផ្សេងៗ សម្រាប់ប្រកួន សង្គ្រាម ដើរផ្លូវមកដល់ទីស្ងាត់នៅនៃព្រះអាកយណ៍ធមនាវតាអ្នកដែល ឈ្មោះក្រងពលី ដោយឈាន ៣ ជំហាន មារីច និងសុភាហុ ក៏ចេញមកប្រាំង ព្រះរាមថ្វែងសរគស្មិត្រូវសុភាហុស្លាប់ មារីចរត់រួចទៅ ។

តមកបានដំណឹងថា ព្រះបាទជនកក្រុងមិថិលា ធ្វើពិធីលើករតនធនូ, ស្វាមិត្រក៏បបួលព្រះរាមព្រះលក្ស្មណ៍ ទៅមើលគេលើកធនូផង, ខណៈដែលធ្វើដំណើរទៅតាមផ្លូវ កាលដល់ទីណា ព្រះវិស្វាមិត្រ ក៏និយាយប្រវត្តិទីនោះឲ្យព្រះរាមស្តាប់រហូតទៅ មុនទឹងដល់ក្រុងមិថិលា បានដោះនាង អហល្យា ឲ្យរួចអំពីពាក្យបណ្តាសានៃព្រះគោតម ហើយទទួលនាងយកជាជាយាដូចដើមវិញ លុះដល់ព្រះនគរហើយ ព្រះស្តានន្ទ-មុនី ជាបុរោហិតព្រះបាទជនក ហើយជាបុត្រព្រះគោតមព្រហ្មឫសី នឹងនាងអហល្យា ដែលជាមាតារួចពាក្យបណ្តាសា ក៏មានចិត្តអំណរខ្លាំងព្រែកឡើង ព្រះវិស្វាមិត្រទូលព្រះបាទជនក សុំឲ្យព្រះរាមនឹងព្រះលក្ស្មណ៍ បានឃើញរតនធនូផង ព្រះបាទជនកបានទ្រង់ដំណាលរឿងរតនធនូ នឹងកំណើតនាងឲ្យស្តាប់ ដល់វេលាលើក គេក៏ប្រជុំពួកក្សត្រកំឡោះៗ មកដាស់ប្រជែងរួមទាំងព្រះរាមផង តែក្សត្រឯទៀតលើកមិនរួច ព្រះរាមលើក រួចដោយងាយ ហើយទាញយឺតខ្សែធ្នូមក ដងធនូក៏បាក់ត្រង់ពាក់ កណ្តាល ព្រះបាទជនកទ្រង់សោមនស្សនឹងព្រះរាម ទើបលើកនាងសីតា

ឲ្យជាអគ្គមហេសីនៃព្រះរាម បញ្ជូនទូតឲ្យមកអញ្ជើញព្រះបាទទសរថឲ្យទៅក្នុងពិធីអភិសេកសមរស ។

កថានេះទៅជារឿងអស្ចារ្យគួរជួបគ្នាឯង ទើបសូមអធិប្បាយឲ្យពិស្ដារបន្តិច គឺកាលព្រះរាមអភិសេកនឹងនាងសីតាហើយ ក៏លើកទ័ពត្រឡប់ទៅក្រុងស្រីអយុធ្យា មកដល់ពាក់កណ្ដាលផ្លូវក៏ប្រទះនឹងបរសុរាមមកខាំងទទឹងមុខ តាមនិស្ស័យបរសុរាមជាអ្នកស្អប់ក្សត្រ កាលឃើញក្សត្រក៏គិតតែនឹងសម្លាប់ចោល ទើបស្រែកឲ្យព្រះរាមដើម្បីឲ្យចូលមកច្បាំងគ្នាថា បានឮកិត្តិសព្ទល្បីខ្ចរខ្ចាយមកថា ជាអ្នកមានឫទ្ធិតេជះគាប លើករែងធនូនឹងយឹតពាល់តែបាក់ ដូច្នេះសុំឲ្យមកលើកធនូព្រះវិស្ណុសិន មានឫទ្ធិស្មើនឹងធនូមុន ហើយសឹមប្រឡងជាដៃគ្នាទៅ ព្រះបាទទសរថភ័យទៅគេបរសុរាមថា លោកកំណើតជាព្រាហ្មណ៍ បានស្បថក្នុងទីចំពោះមុខព្រះឥន្ទ្រថានឹងលើកលែងកាន់គ្រឿងសស្ត្រាវុធ ហើយនឹងតាំងចិត្តបំពេញព្រតតទៅតាមវិស័យព្រាហ្មណ៍ នេះហេតុដូចម្ដេចក៏បានជាមកឱជនជបួលច្បាំងដូច្នេះ បរសុរាមមិនតបតែមកនិយាយនឹងព្រះរាមថា មានធនូសរ ២ ដ៏ជាស្នាដៃព្រះវិស្សុកម្មធ្វើ គឺ ១ ដែលពួកទេវតាថ្វាយព្រះឥសូរ ដើម្បីកម្ចាប់ស្ដេចត្រីបុរៈ ធនូនេះហើយដែលព្រះរាមយឹតបំបាក់ ធនូ ១ ទៀតពួកទេវតាបានថ្វាយទៅព្រះនារាយណ៍មានឫទ្ធិស្មើនឹងត្រីធនូដែលបាក់ ហើយដំណាលគ្នាទៅថា គ្រាមួយនោះ ពួកទេវតា

បានប្រាជ្ញាចង់ដឹងថា ព្រះឥសូរនិងព្រះនារាយណ៍អង្គណាមានបុណ្យជាង អង្គណា ? ទើបនាំគ្នាទៅទូលសួរព្រះព្រហ្ម ក៏ត្រូវញុះឲ្យព្រះជាម្ចាស់តាំងពិធីស្និទ្ធាដើម្បីមើលឫទ្ធិ គ្រានោះព្រះនារាយណ៍គ្រាន់តែស្រែកដោយសូរសីហនាទមួយ ធ្នូព្រះឥសូរក៏ទន់លុតលុក ពួកទេពនិករទើបយល់បានថា ព្រះនារាយណ៍ពូកែជាង ហើយទូលផ្សះផ្សាឲ្យជានិងគ្នាទៅវិញ ព្រះឥសូរគួរព្រះហឫទ័យណាស់ ទើបប្រទានធ្នូនោះទៅកាន់ឫសីទេវរាតនៃវិទេហនគរ, ចំព្រះនារាយណ៍ក៏ប្រទានធ្នូរបស់ព្រះអង្គទៅឫសីឫចិកៃ ឫសី ឫចិកបានឲ្យធ្នូនោះដល់ជមទគ្និ (ជមទគ្និ) ។ បុលចិត្តតែខានបំពេញព្រតជាង ភគបានប្រើធ្នូនេះឡើយ ដកបដល់មរណៈដោយក្ដៅព្រះអរជុន ធ្នូនោះទើបធ្លាក់មកជារបស់បរសុរាម[១] ហើយគោលគេទៅថា ខ្ទង បំពេញព្រតនៅក្នុង មហេន្ទ្រភពក្កិត្តិសព្វថា ព្រះរាមយកធ្នូព្រះឥសូរបាក់ ទើបមិនមកឲ្យយកធ្នូព្រះនារាយណ៍មួនមើល ។

ចំណែកឯព្រះរាមឥតមាន សេចក្ដីខ្ពត់ឡើយ ទទួលយកធ្នូអំពីដៃបរសុរាមមកយកបានដោយងាយ ដាក់កូនសរព្រួញបាញ់បរសុរាម តែនឹកអាណិតដោយគិតឃើញថាការសម្លាប់ព្រាហ្មណ៍ពួកផង គេគាន់ថាមានបាបធ្ងន់ណាស់ គ្រាន់ផ្ដល់បរាជ័យបាន ទើបអនុញ្ញាតឲ្យបរសុ-

---

១ ក្នុងភាគក្រោយ សូមជ្រាបសារៈនៃព្រះសង្ឃញាណប្រាជ្ញ ឡើយក្ស ឈ្មោះព្រះយសអប្បការដ៏-ជាតិរបស់ខ្ញុំ ។ ទើបជាធម៌បកខុសគ្នាពីរ ។

រាម បើសរយកតាមយ៉ាងឯណាមួយ គឺឲ្យបាញ់ទំលាយឋានសួគ៌ ឬញាណ ដែលបានបំពេញមកហើយ ឬមិនឲ្យទំលាយភូមិតាំងពួង ដែលបរសុរាម បានលុះហើយ; បរសុរាមដឹងខ្លួនថាចាញ់ឫទ្ធិព្រះរាមនឹងដាក់ខ្លួនមិនរួច ហើយទើបតបព្រះរាមថា កាលខ្ញុំលើកលោកឲ្យជាទក្ខិណាដល់ព្រះកស្សបៈ ៗ បានយកសន្យាថាខ្ញុំមិននៅក្នុងលោកនេះទៅ តាំងអំពីនោះមកក៏មិនដែលអាស្រ័យដេកនៅក្នុងលោកនេះសូម្បីមួយយប់នេះឡើយ ហេតុនេះទើបសូមកុំឲ្យទំលាយឋានសួគ៌ សូមឲ្យទំលាយភូមិតាំងពួងដែលខ្ញុំលុះហើយនោះចុះ បរសុរាមឃើញច្បាស់ថា ព្រះរាមអង្គនេះនៃធ្លាយទេ គឺអង្គព្រះត្រៃនាថជាម្ចាស់មានជ័យជំនះលើទៅគេអ្នកណា ទប់ទល់គេបា-នុភាពក៏ពុំបាន ទើបមិនគួចចិត្តនឹងការដែលខ្ញុំចាញ់ ។ កាលព្រះរាមថ្ងៃសរទំលាយភូមិញាណដែលខ្ញុំបានលុះហើយ បរសុរាមក៏លាត្រឡប់ទៅមហេន្ទ្រគីរី តាំងបំពេញព្រតតទៅ ឯធ្នូនោះព្រះរាម ប្រគល់ទុកនឹងព្រះពរុណឲ្យរក្សាទុក ហើយស្តេចយាត្រាថ្វាយព្រះនគរ ( ប្រាកដក្នុងរឿងរាមកេរ្តិ៍ថា បើធ្នូសម្រាប់អន្តរាក់ទៅ ក៏ទៅដំរាយកអំពីព្រះពរុណទៅប្រើ, ក្នុងរឿងរាមកេរ្តិ៍ ពោលដល់រាមសូរដាក់ជើងតំឡើង ដែលសំខាន់មាន ២ អន្លើគឺ:

ក- ពោលដល់ការច្បាំងរវាងអរជុននឹងបរសុរាម នៃពាំបាកសង្កេតណាស់ ព្រោះហៅឈ្មោះមិនដូចគ្នា ខាងខ្មែរនឹងសៀមហៅថា រាមសូរ

ហើយខុសគ្នាត្រង់ដែលថា កមស្សូ ជាយក្សគ្មានស្រុកទេសនៅ-សារហេតុដែលច្បាំងគ្នា ខាងខ្មែរយើងថាកមស្សូទៅប្រែះនាងមេខលា បានសេចក្តីស្រឡាញ់ទើបមិនយោយដៃចង់ ព្រះអរជុនមកប្រែះក៏កើតច្បាំងគ្នា ព្រះអរជុនបាញ់ប្រៀបក៏ត្រូវកមស្សូចាប់បោកនឹងគល់ព្រះសុះបុរុស្លាប់ ។ រឿងនេះឃើញមិនសមហេតុផល ។

១-កមស្សូមកទទឹងមុខព្រះរាម ពាល់នៃកើតហេតុច្បាំងគ្នាត្រង់នេះឃើញថាកមស្សូមានឫទ្ធិតេជៈច្រើន ការច្បាំងប្រើធនូ មិនដូចកាលច្បាំងនឹងព្រះអរជុន ការដែលបរសុរាមបាញ់ព្រះរាមចន្ទ្រនេះ មានជាគួយាងនៃ.១ ប៉ុណ្ណោះ ដែលអ្នកជានារាយណ៍អវតារមកមុន ត្រូវបាញ់អ្នកដ៏ជានារាយណ៍អវតារមកក្រោយ ព្រោះអ្នកមកមុននោះបានធ្វើកិច្ចតាមនាទីរបស់ខ្លួនរួចហើយ តែមិនទាន់បេរិលរើដោយបានសុំអាំងឲ្យមានអាយុវែង, ក្នុងមហាភារតៈ ទឹងគម្ពីរបុរាណខ្លះដែលតែងសម្រាប់សំដែងប្រវត្តិនិងសរសើរព្រះក្រឹស្ណាតែនោះ មានពោលដល់បរសុរាម ត្រឹមតែជាព្រាហ្មណ៍អ្នកជំនាញក្នុងវិជ្ជាយុទ្ធសាស្ត្រ ហើយទឹងជាមិត្តរបស់ព្រះក្រឹស្ណៈប៉ុណ្ណោះ មិនបានហៅជានារាយណ៍អវតារទេ ទើបបានសេចក្តីថា បរសុរាមក្នុងគ្រាទី ៨ នោះជា " អវតារក្រៅដំណែង " ដោយពិត ។

លុះចូលដល់នគរស្រីអយុធ្យាហើយ ព្រះបាទទសរថទ្រង់ព្រះតំរិះនឹងអភិសេកព្រះរាមជារាជទាយាទ នាងគម ឈ្មោះមន្ត្រាទូលញុះញង់នាងកៃកេយី ទើបសុំឲ្យព្រះភរតៈបានជាយុពរាជ ហើយឲ្យនិរទេសព្រះរាមទៅនៅព្រៃ ១៤ ឆ្នាំ តមកក៏ពណ៌នាដល់ការដើរព្រៃរបស់ព្រះរាម, ឯព្រះភរតៈមិនព្រមទទួលរាជសម្បត្តិ ទ្រង់ឲ្យបងថ្នល់ទៅទូលព្រះរាម តែព្រះរាមមិនព្រមត្រឡប់ ។

(ព្រះលក្ខណ៍បានតាមស្តេចទៅផង) ក្សត្រទាំង ៣ គឺព្រះរាម នាងសីតានិងព្រះលក្ខណ៍ចូលកាន់ព្រៃទណ្ឌកៈ អាស្រ័យនៅក្នុងព្រៃនេះ ១០ ឆ្នាំ ហើយចេញទៅអាស្រមនៅក្នុងសំណាក់មហាឫសីនិងទេពឫសីផ្សេងៗ ក្នុងទីបំផុតបានទៅរកអគស្ត្យមហាមុនីៗ បានទទួលដោយស្រួល ហើយថ្វាយព្រះកាំទណ្ឌសំខាន់ដល់ព្រះរាម គឺព្រះកាំទណ្ឌព្រះនារាយណ៍ ១ ព្រះកាំទណ្ឌឈ្មោះព្រហ្មស្ត្រ ១ បំពង់សរដែលមិនចេះអស់ (ដែលព្រះឥន្ទឲ្យ) ១ ព្រះខ័នបន្ទាយមាសព្រមទាំងស្រោម ១ ព្រះរាមទទួលរបស់អំណោយនេះទុកហើយ សុំឲ្យព្រះមហាមុនីបង្ហាញទីកន្លែងដែលគួរនឹងសាងអាស្រមទៅបាន ព្រះអគស្ត្យទូលថា ចម្ងាយ ២ យោជន៍អំពីអាស្រមនេះទៅមានទីល្អហៅថា "បញ្ចវដី" នៅជិតទន្លេគោធាវរី ក្សត្រទាំង ៣ ក៏នាំគ្នាទៅតាំងអាស្រមនៅទីនោះ ជាទីសុខស្រួល ក្រោយមកបានកើតរឿងនឹងនាងសូរបនខា ជាកនិដ្ឋភគិនីរបស់ទសកណ្ឋនាំនេះជាមូលហេតុ

ឲ្យខ្ទេចបាក់បង់ញាតិវង្សទាំងគោត្រត្រកូលក្រុងខរ, ក្រុងទូសណ៍ទាំងត្រីសិរ មកច្បាំងសងសឹក ក៏ត្រូវសរព្រះរាមស្លាប់ទៅទៀត នាងទ្រនីទៅលង្កា ទូលប្តឹងដល់ក្រុងរាពណ៍ ទាំងរៀបរាប់សរសើររូបឆោមនាងសីតាដោយនានា ប្រការ ពាល់តែក្រុងរាពណ៍កើតសេចក្តីប្រាថ្នាចង់បាន ឲ្យមារីចនិរ-មិត្រខ្លួនជាប្រើសមាសទៅបញ្ឆោតព្រះរាម ក្រុងរាពណ៍ប្រែខ្លួនជាឫសី ទៅចង់នាង កាលនាងមិនព្រមដោយស្រួល ក៏កំហែងចាប់ពាហោះ ទៅ ជតាយុបក្សព្រាជបានឃើញ ចូលប្រឹងចឹកដណ្តើមយកនាងសីតា តែត្រូវក្រុងរាពណ៍ពោលនឹងព្រះខ័នត្រូវបាក់ស្លាប ផុតពីនោះ នាងសីតាបានឃើញពានរ ៥ ទើបដោះស្បៃអំពីខ្លួនជ្រុះទុកឲ្យព្រះរាម ។ ព្រះរាមកាលទ្រង់ជ្រាបថា នាងសីតាបាត់ទៅ ក៏រលះរលាំងតាមរក ប្រទះជតាយុក៏ទូលតាមដំណើរ, ព្រះរាមបានកាប់នាងរាក្សសីឈ្មោះ អយោមុខីជួយតពន្ធឲ្យត្រឡប់មានរូបល្អដូចដើម, ហើយដើរតទៅរក សុគ្រីព ដើម្បីឲ្យជួយរកនាងតទៅ ។

ក្សត្រទាំងពីរមកដល់ភ្នំឫស្យមុខ ជិតភ្នំមល័យជាទីលំនៅសុគ្រីព ។ ឲ្យហនុមានទៅទូលសំដែងមេត្រីមុន ហើយទាំងពីរនាក់ក៏ដំណាល រឿងរ៉ាវឲ្យស្តាប់ទៅវិញទៅមក ព្រះរាមនិងសុគ្រីពក៏ធ្វើសត្យសន្យាគ្នា ចំពោះមុខភ្លើងជាសម្ពន្ធមិត្រនឹងគ្នា ហើយនឹងជួយគ្នាឲ្យសម្រេចសេចក្តីប្រាថ្នាគឺព្រះរាមនឹងផ្ចាញ់ក្រុងពាលី, សុគ្រីពនឹងជួយរកនាងសីតាហេតុ

ដល់ដៃយក្សម្នាក់ក្រុងកពណ៍ ហើយនិងចំណាលរឿងដែលក្រុងទៅទេស
តាំងនាងម៉ែទេពីសំឡាញ់ ក៏ក្រុងក្រុងរាពណ៍ដណ្តើមយកទៅ ព្រះរាមក៏
ក្រោមផង បើបរទូលថា នឹងជួយរកកូនការដែលលួចប្រពន្ធគេ សុ-
គ្រីពទូលថា ពាលីមានឫទ្ធិខ្លាំងណាស់ ហើយក៏ដំណាលរឿងទុក្ខ នឹង
សុំឲ្យព្រះរាមលប្ងួតមើល ព្រះរាមក៏សំដែងឫទ្ធិបាញ់ព្រួញដើមត្នោត
ធ្លោះទៅឆ្ងាយ ១៤ យោជន៍ទីទៃផងរបោះ ដើមត្នោតធំទាំង ៧ ហើយធ្លុះ
ហួសទៅជលក្នុងសមុទ្រ សុគ្រីពត្រេកអរណាស់ក៏ក្រាបញព្រះរាមទៅ
សង្គ្រាមក្រុងពាលីកន្លែងនោះ ៗ ព្រះរាមអភិសេកសុគ្រីពជាព្រះរាជាគ្រង
នគរកេសកិន្ធ សុគ្រីពហៅសេនាពានរមកប្រជុំគ្នា ហើយចាត់ឲ្យចែកគ្នា
ទៅតាមរកនាងសីតា ។ គឺអង្គទកាន់កាប់ពលមួយពួក ទៅស្វែងរកទិស
ទក្សិណ ហនុមាន ជម្ពូពាន នីលនន សុសេន កាន់កាប់ពលមួយពួក
ទៅស្វែងរកទិសបស្ចិម សតពលកាន់កាប់ពលមួយពួកទៅស្វែងរកខាង
ទិសឧត្តរ ។

ពួកវីរទក្សិណ ត្រាច់ទៅតាមផ្លូវក្នុងព្រៃ ក្នុងទីបំផុតបានជួប
នឹងបក្សីរាជ ឈ្មោះសម្ពាទីជាបងរបស់ជតាយុ នៅក្នុងគុហា ប្រាប់
ដំណឹងនាងសីតានឹងបក្សីឃើញជួបទៅលង្កា ។ គ្រានោះហនុមានយកអា-
សាឆ្លងសមុទ្រទៅលង្កា នាងសុរសាដ៏ជាមាតានៃនាគទាំងឡាយនិមិត្ត
ខ្លួនជាយក្ខិនី ខ្ទប់ផ្លូវហនុមាន ៗ (មានត)

# ព្រះរាជក្រឹត្យក្រមចៅហ្វាយស្រុក

## រជ្ជកាលព្រះបាទសម្ដេចព្រះឧទ័យរាជាធិបតី

## (ព្រះអង្គបន្ទួ) ភាគ១

បើនឹងរើសរកឲ្យជាចៅហ្វាយស្រុកនោះ កុំឲ្យចិត្តៈអាលោភពេក បើលោភៈពេកហើយ បៀតបៀនរាស្ត្រ អស់រាស្ត្រចំណុះស្រុកពុំចូលចិត្ត ហើយកុំជាពេក បើជាពេក អស់រាស្ត្រចំណុះស្រុកពុំខ្លាច លុះជាកណ្ដាលទើបគាប់ ហើយកុំកឹងពេកកុំខ្លួរពេក កុំរឹងកុំទន់ កុំឆាប់ពេក កុំយូរពេក (តាំងនេះ) អស់រាស្ត្រចំណុះស្រុកពុំចូលចិត្តទេ ។ បើខ្លួរពេកបើយូរពេក មិនបានព្រះរាជការ លុះជាកណ្ដាលទើបគាប់ ។ រីចៅហ្វាយស្រុកនោះឲ្យដឹងអាត្មា ឲ្យដឹងជាទៀង ឲ្យរឹងជាគាប់ ឲ្យដឹងជាយូរ ដ្បិតចៅហ្វាយស្រុក ជាគ្រូរាស្ត្រចំណុះស្រុក ជាឪពុកម្ដាយអស់រាស្ត្រចំណុះស្រុកផង ។ ឯជាចៅហ្វាយស្រុកនោះឲ្យរៀរ៥ចំពូក (គឺ) កុំសម្លាប់សត្វឥតទោស ១ ឲ្យរៀរយករបស់ទ្រព្យគេពុំឲ្យថ្ងៃ ១ កុំឲ្យល្បួងប្រពន្ធគេ ១ រៀរកុំស្រដីកុហកភរកុហកលេង ១ រៀរកុំសេពសុរា ផឹកស្រានាថ្ងៃសីល (ឬ) ក្រៅអំពីថ្ងៃសីល ១ ។ កុំបីមានចិត្តលោភ ទោស មោហ ភយា ឆន្ទា (គតិ) ឡើយ ឲ្យដឹងបុណ្យដឹងបាប កុំឲ្យប្រមាថព្រះពុទ្ធ ព្រះធម៌ព្រះសង្ឃ ចាស់ទុំគ្រូឧបជ្ឈាយ៍ ម្ដាយឪពុក អ្នកចាស់អ្នកទុំ ហើយកុំគិតល្មោភទ្រព្យគេ ឲ្យសង្កាត់ខ្ញុំ ណៅ (ម្យ៉ាង) ឯងជាឪពុកម្ដាយអស់

កស្រ្តីចំណុះស្រុកទាំងឡាយ ឲ្យសង្កាត់ធ្វើស្រែចំការរក្សាព្យាធិណាំ ផ្សារដែលលក់ទិញធ្វើការជោរជង់ទាំងឡាយ បើមានបើត្រូវសារពើការជន នឹងឲ្យប្រាមប្រាប់ ក៏សឹងឲ្យព្រម (គ្នា) ។ (ចៅហ្វាយស្រុក) ឯងជាម្ដាយឪពុកអស់កស្រ្តីចំណុះស្រុក ឲ្យគន់មើលឲ្យដឹងកំសត់ (ខ្សត់ក្របស់) កស្រ្តី ឲ្យត្រូណាអាស្រូវកស្រ្តីចំណុះស្រុក ហើយបើមានមនុស្សកំណាចកាចចេញទៅរកគក្បាគយករបស់ទ្រព្យលក់ពិន័យធ្វើទុក្ខបុកហិនអស់កស្រ្តីចំណុះស្រុកក្តី ចេញទៅជាចោរលួចប្លន់កាប់សម្លាប់អស់កស្រ្តីចំណុះស្រុកក្តី នោះឲ្យចៅហ្វាយស្រុកឯងសង្កាត់រកមនុស្សកំណាចនោះឲ្យឃើញហើយឲ្យយកមកធ្វើទោសាដោយទូវទោសធ្ងន់ស្រាល ដូចម្ដាយចិញ្ចឹមកូន ។

ច្បាប់បើនឹងចិញ្ចឹមជាចៅហ្វាយស្រុក ឲ្យចេញទៅរក្សាកស្រ្តីស្រុកក្រៅនោះ ឲ្យមន្រ្តីធំជំនុំពិចារណានឹងរក ឧកញ៉ា ពញា ព្រះ ឯណានឹងឲ្យទៅជាចៅហ្វាយស្រុកក្តី ប្រើបានស្រេចហើយឲ្យក្រាប (បង្គំ) ទូល បើសព្វព្រះរាជហឫទ័យព្រម នឹងឲ្យទៅជាចៅហ្វាយស្រុក ស័ក្តិ ៦ ហ៊ូ[១] ពាន់ជាដើម ។ បើអស់កស្រ្តីចំណុះស្រុកចូលចិត្ត រាជការក៏បានផង

---

• សព្វថ្ងៃក្លាយមកជាហ៊ូពាន់ ។ ឯពាក្យថា ហូពាន់ តាមការហៃប្រែថា ក្បាលពាន់ គឺរាប់យកចំនួនមនុស្ស ១០០០ នាក់ ស័ក្តិ ៦ ហូពាន់ បានសេចក្ដីថា មានអំណាចត្រួតមនុស្ស ៦០០០ នាក់ឡើងទៅ ។

ទើបឲ្យចំណុះ (ជា) ទៅហ៊ុ ៣ ស្រុកស័ក្តិ ៨ ហូពាន់លើសមិនដើម ។ បើអស់ពស្រុកចំណុះចូលចិត្ត ហើយកជការក៏បានធន[1] (ទៀត) ទើបឲ្យយកទៅហ៊ុយស្រុកអោះឯងចំណុះលើកក្បៀង ឲ្យជាទៅហ៊ុយស្រុកស័ក្តិ ១០ ហូពាន់លើសមិនដើម ។

មួយទៀត ដ៏ទៅហ៊ុយស្រុកឲ្យដណ្ដឹងគន់យល់ អស់ចំណុះស្រុកផង ឲ្យដឹងក្រឲ្យដឹងងាយ ដឹងនឿយដឹកព្រួយ ឲ្យដណ្ដឹងគន់យល់អស់កជការញាក់ង៉ាសេក្តទៅហ៊ុយតែងនឹងយកពន្ធឧបករណ៍[2] ថ្វាយព្រះថ្វាអ្នកជាម្ចាស់ ទោះញាក់ង៉ាខុន ពួកញាក់ង៉ាសេនាក្រ កុដម្ភ ខ្ញុំ ពន្ធស្បូវដឹងកប[3] ធនតាំងឡាយ ឲ្យទៅហ៊ុយស្រុកជាស់ក្បៀនអស់ ញាក់ង៉ាតាំងអម្បាលណា ឲ្យសង្កាត់ខ្ញុំឃុំគរកស្រង់ដោយមុខងារ កំណាន់ទីទៃៗ ឲ្យត្រាពិនិត្យរៀងដិតជុំ ឲ្យដំណើរនាំចូលទៅថ្វាយហើយ

---

១ សេចក្ដីផ្ដន្ទាទោសនឹងសេចក្ដីខាងលើនេះ ទើបគួរបាប់ការលេខក្ដីថា មន្ត្រីដែលបានឡើងស័ក្តិ ៩ ហូ [illegible] កុលបើ [illegible] ធ្វើកជ [illegible] រយ៉ូទៅ កស្ត្រីកំនាស្រឡាញ់កប់អាន តាំងភាគផ្នែក កជការ ក៏រាជការល្អផង ទោះត្រូវបានឡើងស័ក្តិថែមទៀត ។ ២ ពន្ធអប្ប [illegible] ប្រហែលជា ពន្ធអ្នកទេ ព្រោះខ្មែរប្រើពាក្យនេះសំដៅ [illegible] ស្លួ [illegible] ប្រាក់ [illegible] ធ្លាប់ជា ស្លាយអាករ ឬស្លាយសារអាករ ដូចគ្នាដែរ ។ ៣ នេះជា ឈ្មោះ [illegible] ភាសាខ្មែរយើង ដែល មណ្ឌលក្រៅត្រូវបង់ជូនរដ្ឋ [illegible] ពាក្យ [illegible] សៀមថា [illegible] ។ តែខ្មែរ [illegible] ប្រើ [illegible] ថ្ងៃនេះ ពាក្យថា [illegible] ដែលអ្នកជាដោយ [illegible] ។

ព្រះរាជតាំងបើកឲ្យយកខ្ញាត់ស្រុក[១] ដោយនូវច្បាប់ហោង ។ បើគួរនោ នឹងយកពន្ធស្រូវនោះ ពោះអស់ព្រះអង្គនូវព្រះវង្សានុវង្សនូវមុខមន្ត្រី សេនាបតីធំ-តូច នូវជាតាន់នៈនផន ពោះមហាគនូវសារពើពល នូវក្រស្ត ផនតាំងតួង បើធ្វើស្រែក្នុងខេត្តខណ្ឌណា ខាងស្រុក ។ កញ្ញាផាំ ចៅហ្វាយស្រុក ប៉ុន្មាន ១ ក្ដី ឲ្យចៅហ្វាយស្រុក យោកក្បាត់ទៅរមៀនទៅបាននូវញាក់អ៊ារ ខុន ពលទេពជន ឲ្យសន្ធាតខ្ញុំឃ្លាតកេយកពន្ធ (ពោះ) ១០ ឲ្យយក ១ ក្ដី ២០ ឲ្យយក ១ ក្ដី ៤០ ឲ្យយក ១ ក្ដី ឲ្យរះគិតឲ្យដឹតពិនិត្យយកឲ្យសព្វគ្រប់ ឲ្យបៀសវៃតពលពួកដីរសេះនូវស្រូវក្នុងមី ។

រីក្រៅអំពីនោះ ពោះស្រូវអស់ព្រះវង្ស ឲ្យកាំឡោះធ្វើស្រែក្ដីស្រូវ ព្រះរាជវង្សានុវង្ស នូវមុខមន្ត្រីសេនាបតីធំ-តូច នូវជាតាខាងផនឲ្យធ្វើស្រែក្ដី ពោះក្រស្ដផាស់ធ្វើស្រែ ជាបេរអម្រស់ខ្លួនឯង (ក្ដី) ១០ ឲ្យយក ១ ឯមហាគនូវពលបន្ទាស់ផ្លាស់គ្នាចេញក្បួលអ៊ារធ្វើរាជការក្នុងនោះ ២០ ឲ្យយក ១ ដ្បិតស៊ីងទៀយ ព្ពាយ ៦ ខែនៅក្នុងរាជការ ។

ឯពលស្នួយដ្បិតបានយកមុខអ៊ារពីរ៉ះហើយ ឯនូវស្រូវ ៤០ ឲ្យយក ១ ហើយក៏ឲ្យចៅហ្វាយស្រុកយកទៅប្រើឡើយ បើមានសឹទលើកមក ទៀបទើបឲ្យយកទៅចំពោះនៅបន្ទាយ ។

---

១ ត.ក្បួន ខ្ញាត់ សព្វថ្ងៃសំដៅ ក្នុងប្រាក់ថ្នូរបស់ទ្រព្យដែលហុតជាពន្ធដាក់ឃ្លាំង ។

ឯស្រូវចៅហ្វាយស្រុកឯង នូវដំរប់ ចៅមឿង ចៅបាន យោក្របត់ ស្នូកា ក្រឡាបញ្ជី ក្រមការផងទាំងអម្បាលណោះ សឹង ១០ ឲ្យយក ១ ដូចអស់ក្រស្តាំងថ្កាស ។

ឯពលទេពស្រាប់ព្រះមហាឧបរាជ នូវសម្តេចព្រះមហាឧបរាជ នូវសម្តេចព្រះរាជមាតា តែងយកស្រូវពន្ធអំពីកម្មោះដោយហ្លួងហ្វាយ[១] នោះឲ្យចៅហ្វាយស្រុកដណ្តឹងគន់យល់មើលករកតែងលើអស់ពលទេពក្រៅអម្បាលណោះឲ្យយកពន្ធ បើបានស្រូវនោះប៉ុន្មានៗឲ្យចៅហ្វាយស្រុក (កត់) ត្រាដោយនូវញាក់ផ្កាពលទេពទាំងៗហើយនាំកម្មោះនោះទៅដល់ចៅហ្វាយពលទេព ឲ្យក្រាប (បង្គំ) ទូលហោង ។

បើចៅហ្វាយស្រុកនូវអស់ញាក់ផ្កាទាំងអម្បាលណោះ ពុំយកឲ្យក្រាប (សា) ដូចព្រះបន្ទូលពិសេសនេះហើយ ចៅហ្វាយស្រុកនូវអស់ញាក់ផ្កា មានបាបជាទម្ងន់ (ទោះ) បើចៅហ្វាយស្រុកនូវខុនញាក់ផ្កាទាំងនេះ ពិនិត្យដិតដុំ ដូចក្រមច្បាប់នេះហើយ ឲ្យអស់ទេវតាផងចំរើនស្រីសួស្តី ហោង ។

បើយកពន្ធបានច្រើនហើយឲ្យបែងជាភាគ ១០ ភាគ ១ ព្រះរាជ-ទានបើកឲ្យចៅហ្វាយស្រុក ឲ្យចែករំលែកអស់ដំរប់ យោក្របត់ ចៅ

---

១ ហ្លួងហ្វាយ តាមពាក្យ សម្រាប់ ប្រាជ្ញ ជាចំណែកបរិក្ខារ ៖ ដោយហ្លួងហ្វាយ ព្រះអង្គ ទាំង ៣ គឺ ជាឃុំចំណែកដាច់របស់ក្សត្រហ្លួង ទាំង៣ ព្រះអង្គនោះឯង ។

មឿងទៅបាន សព្វញាក់អាករផ្ទេងស្ពំនោះឯង ឯស្រូវភាគ ៩ ឲ្យថែម ជាភាគ ១០ វិញទៀត ភាគ ៩ ជាព្រះរាជទ្រព្យ ភាគ ១ ជាព្រះរាជទាន ចេញឲ្យអស់ពលទេពក្រៅថែកគ្នារហាង ។

មួយសោត បើបេះច្បាប់ទៅហ្លួយស្រុកក្រៅ អស់អាជ្ញាទាំងពួង ចេញមកដល់ទៅហ្លួយស្រុក បើអាជ្ញាព្រះបាទអ្នកជាអម្ចាស់កុំឲ្យទៅហ្លួយស្រុកផ្គង់ស្បៀងឡើយ ឲ្យទៅហ្លួយស្រុកយកចំបង(១) នូវកម្មោះដោយព្រះអង្គឲ្យផ្គង់ស្បៀងអាជ្ញា ដោយបម្ចាស់ទីទៃ ៗ នោះ បើអាជ្ញានោះមានទំនិញនូវប្រាក់ទំនិញ សារពើអ្វី ៗ កុំថែក(២) អស់រាស្ត្រផង បន្ទោករបស់គេ (គ្រឿ) ឲ្យទិញដូរឲ្យថ្លៃដូចបេបឈ្មួញទាំងពួង ហើយកុំឲ្យរះឈ្មៀស(៣)រទេះ នូវគោក្របី នូវទូកព្រាកថែរ ក្របិទ ថ្លាលបង្គូក ហើយកុំឲ្យរៃរកភាគក្បាតយករបស់គេ វាយដ្ឋាយកអង្គរស្រា ផេះដូងបេះ ស្លាម្លូបេះបោបសារពើដំណាំធងទាំងពួង ហើយកុំឲ្យរឹសយកដំរីសេះ រទេះគោក្របីតែមាន់លលកគ្រួចទាំងនូវសារពើទ្រព្យគេផង ។ បើអាជ្ញានូវកំណាចឯណា ធ្វើនូវអំពើដូច្នេះ ហៅបង្ហិទថ្លូក្រោម ឲ្យកោលាហល

---

១ ពាក្យច្បាប់ចាស់ដែលបានរៀនឹងសព្វថ្ងៃនេះ គេសរសេរជា (ឈ្មោះ) ត្រូវខឹងបៀកសរសេរសព្វថ្ងៃ កម្សាងឬចំបង ។ ពាក្យនេះប្រែលជាសំដីយកខមនុស្ស ។ ពួកពលជាពួកធ្វើស្រែរបស់ព្រះអង្គ ធ្វើវាបពួកដែលហៅថាកម្មោះផ្លូវដោយដែរនេះដឹង ។ ២ ពាក្យថា "កុំថែក" នេះសព្វក្ដីមិនសូវច្បាស់ប្រហែលជាកាចតាក់ទទឹង ? បើនេះជាច្បាស់ "កុំបោកកំរាយស្ត្រ ផងឲ្យបានសេចក្ដីក្ដៅក្រហាយ" ។ បើមិនដូច្នេះ គឺ "កុំ (សុំ) ថែក សំ ស្រ្តផង" បានពាក្យ "សុំឬសូម" ដោយសេចក្ដីភ្ញាក់ភ្នាក់របស់អ្នកបារ ។ ៣ ឈ្មៀស ប្រែថាស្ទាត់កេណ្ឌយក ។

ឥសិកស្ត្រីផងទាំងឡាយ ឲ្យចៅហ្វាយស្រុកពិចារណា បើ (ជា) អាជ្ញា អំពីព្រះបាទអ្នកជាអម្ចាស់បរមបពិត្រ ត្រង់ផ្ទៃក្រោម នោះឲ្យចាប់ប្រគោះ នាំចូលទៅ ។ បើអាជ្ញាអំពីអស់ព្រះអង្គ នូវសព្វមុខមន្ត្រីគោះមហាត នូវពលនូវព្រៃផ្សារឯណា បើធ្វើនូវអំពើកំណាចផ្ទួរទោះ ហើយឲ្យចៅហ្វាយស្រុកចាប់ច្រកឃ្នោងឲ្យខ្ជាប់ នាំចូលទៅដល់មន្ត្រីជាធំឯកន្ទ ឲ្យជំនុំពិចារណា ធ្វើដោយទោសានុទោសឲ្យប្រាកដ ។ បើចៅហ្វាយស្រុកពុំការក្រែងក្រោតដោយចំណុះស្រុកឯងឡើយ ចៅហ្វាយស្រុកត្រូវទោសច្រកឃ្នាងហើយផ្ដុត(១) ចេញពីផ្សារជាកស្ត្រីហោង ។

មួយសោត ព្រះបាទបរមបពិត្រអ្នកជាអម្ចាស់ ព្រះរាជទានបញ្ញើមខ្លួនឯង ឲ្យចេញទៅ (ធ្វើ) ជាចៅហ្វាយស្រុកជាអាពុកម្ដាយអស់រាស្ត្រ ហើយ ពុំបេះគិតការក្រែង វេទាម(២) រក្សារាស្ត្រដោយនូវចំណុះស្រុកឯងឡើយ ហើយយកប្រើធ្វើស្រារតើករាជការទាំងពួងពុំស្មើគ្នា ពុំជំនុំកាត់ផង ជំនុំសេចក្ដីដោះទុក្ខរាស្ត្រ ពុំដោយគន្លងធម៌សុចរិត ពុំពិនិត្យដោយនូវព្រះរាជក្រឹត្យច្បាប់ បើមានរាជការអំពីមន្ត្រីធំឯកន្ទបង្គាប់ទៅ សឹងតែយកប្រើជ្រើសរើសរាជការបង្គាប់ទុះឯង ពុំក្រែងរាទៀយព្រួយ ជារាជរាស្ត្រ

---

១ ពាក្យថា "ផ្ដុត" ប្រែថា ឲ្យដកចេញពីដំណែងងារស័ក្តិ ។ ២ ពាក្យច្បាប់ចាស់សរសេរជា "វេទាម" មិនដឹងជាភាសាអ្វី សេចក្ដីដូចម្ដេច ។ ប្រហែលជា "វេទនា" ទើបបានសេចក្ដីថា "ចៅហ្វាយស្រុកពុំបេះគិតការពារក្រែងរាស្ត្រវេទនាសោះឡើយ" ។

កំសត់ទៀយ ហើយគេកល់ទ្រព្យខុសទំនង (អួស) យកទ្រព្យរបស់ពួកសិងី មាន ហើយពួកស្ដេចណាៈស្រុកចាំងខ្លាច ពុំក្លាចិត្តហើយពុំតែខ្វាត់ខ្វាយ បេញោទៅនៅដោយសព្វស្រុកសព្វអន្ទើងក្រៅ នឹងយក (មក) ប្រើពុំបាន ទៀយ ហើយថែរខ្វែប្រែចិត្តពុំខ្លាច ចូលទឹងមនុស្សកំណាច ធ្វើជាចោរ ខយវិលមកលបលួចប្លន់យក គាគ្រប់ ខ្សែទ្រព្យរបស់បង្ហិនអស់ក្រស្ដែផង ។ ដឹ មិនតែប៉ុណ្ណោះទៀយ ពុំខ្វែប្រែជាសត្រូវវិញកំសាំមាន ក្រស្ដេចខ្ទះពុំ ក្ដៅចិត្តណាស់ ហើយ ៖ ពុំនាំប្រពន្ធកូនពុំតែហួសចូល ទៅនៅដោយខគរ ប្រទេសឯទៀតវិញ ដ្បិតតែគាជ្រាធ្វើទុក្ខពុកបង្ហិនយកទ្រព្យរបស់ហើយ នោះទៅហ្វាយស្រុកពុំការគ្រងណ្ដើងគន់របស់ទៀយ (១) ទើបគេគេដូច្នេះ ឲ្យទៅហ្វាយស្រុកគិតពិនិត្យឲ្យទៀងទាត់ កុំបំលំអៀនខ្សែព្រះរាជការ ប្រញាប់ខ្សែព្រះត្រៀមដីការនេះហោង ។

ចាប់ឯទៅហ្វាយស្រុកក្រៅនោះ ចោះសក្តិ ៧ ហូពាន់ក្តី សក្តិ ៨ ហូពាន់ក្តី សឹងរិះគិតថ្លង់តាក់តែងព្រះរាជការដោយខ្សែស្រុកឯងទាំងៗ ពុំដែលមានគេធ្វើយព្រងើយបង្វៀត ទឹងរាជការខ្ចងឯងទៀយ ហើយ ប្រចាំតែពីកន្ទប្រដៅទៅ ពុំដែលមានដូច្នេះទៀយ ដ្បិតទៅហ្វាយ ស្រុកក្រៅនោះ សឹងឲ្យដំខប់ ហោកក្បាត់ , ស្មុគ , គ្រឡាបញ្ញី

១ គឺៈជាហ្វាយស្រុកពុំរកចិត្តទុកដាក់ រក្សាការងារក្រស្ដែមិនស្ទះបញ្ញាក់កន្ទុំ ផ្ដៃ បណ្ដោយឲ្យអព្វាធ្វើបាបសង្កត់សង្កិនក្រស្ដែ ។

ចៅមឿង ចៅភូន[១] ក្រមការក្នាក់ងារទាំងនោះ មកជំនុំរះគិតពិនិត្យ ពិចារណា គាត់តែងរាជការផែនទាំងពួង ដោយខ្ញូវស្រុកធំតូច កុំដែល សល់ដល់ (មួយ) ថ្ងៃ ឡើយ ៗ បើកើតកោលាហលកង្វល់ក្នុងស្រុកឯណានោះ ទោះកើតចោរក្តី ទោះដំរីខ្លាក្រពើសារពើសត្វផងសាហាវក្តី ទោះមាន អាជ្ញាផង មកធ្វើទុក្ខលកពន់ពេកគេគ្រាកក្រៅក្នុងស្រុកក្តី សឹងនាំជំនុំរះគិត ពិនិត្យពិចារណាពិភាក្សាឲ្យប្រាកដហើយ ក្នាក់តែងឲ្យរក (ចាប់) កុំឲ្យ មន្ត្រីឯក្នុងព្រួយចិត្ត ឡើយ ទោះរកបានហើយទើបឲ្យមកប្រាប់មន្ត្រីឯក្នុង ឲ្យបានដឹងផង ៗ ឯច្បាប់បើមានជំនុំរះគិតសព្វថ្ងៃទៅហើយ រឺគិត នោះក៏ យល់ច្រើនសព្វគ្រប់ឯបៀនបើរៀនច្រើនហើយ (ក៏) ចេះច្រើន បើរៀន តិចចេះតិច បើចៅហ្វាយស្រុក ខ្ញូវជំទប់ យោក្បាត់ ក្រឡាបញ្ជី ចៅ មឿង ចៅបានខ្ញូវក្រមការផងទាំងអម្បាលនោះ កុំខំឃ្នាតសង្កាត់គិត ពិនិត្យអស់ព្រះរាជការដោយក្នាក់ងារឲ្យបានសព្វគ្រប់ ដូចព្រះរាជការ ប្រញាប់ប្តូរសព្វគ្រប់នេះឡើយ ៗ ចៅហ្វាយស្រុកខ្ញូវអស់ក្នាក់ងារ មាន ទោសឥតប្រណីត្រូវក្តី ហើយពិន័យដល់ឧដុង្គសក្តិ[២] ដាក់បញ្ចាក់ប្តូវិញ កុំឲ្យគង់ជានាហ្មឺនស្រដៃព្រះរាជការឡើយ ៗ.

---

១ ចៅមឿង ប្រែថា ម្ចាស់ស្រុក ។ ចៅបាន: ប្រែថា ម្ចាស់ភូមិម្ចាស់ភ្នំ ។ ២ ឧដុង្គសក្តិ ប្រហែលជាក្លាយមកពីពាក្យថា រត្នសក្តិ ដែលប្រែថា យសស័ក្តិខ្ពង់ខ្ពស់ ឧត្តម ថ្លៃថ្លា ។

ព្រះបន្ទូលពិសេសត្រាស់ឲ្យមកដំណល់ទុកលើត្បូង ចៅហ្វាយស្រុក ស័ក្តិ ១០ ហ៊ូពាន់ ឲ្យពិនិត្យជិតដុំអស់ករការផែនតាំងពួនជួរក្រមប្រាប់ ហើយឲ្យចៅហ្វាយស្រុកត្រាចម្រើនបញ្ជីអស់ចំណុះស្រុកឲ្យដឹង អ្នកជាព្រៃងារ(១) នួរកម្លោះ(២) មហាត(៣) នូវពលបំរេស(៤) នូវខ្ញុំគេតាំងពួន នោះខ្សោយខ្សាយលីឃ្លោល(៥) ពិការចាស់ជរាក្ដី ឲ្យដឹងជាយជំពូកចៅហ្វាយនាយទីទៃ ៗ ឲ្យសព្វគ្រប់ បើនរណាលាក់គ្នាពុំឲ្យកត់បញ្ជី លុះផល់រកចៅយល់ជាលាក់គ្នាមែនពិតហើយ ឲ្យចៅហ្វាយស្រុកយកអ្នកដឹលាក់នោះមកប្រែកឃ្លានកយនូវពាក់ ។

---

១ ព្រៃងារៈ តាមវចនានុក្រមខ្មែរថា សំដៅបក្ខពួកនៃមនុស្សឬវង្ស គឺពួកនៅក្នុងថ្នាក់ទី ៣ ក្នុងវណ្ណ ៤ ពួក ឯពួកថ្នាក់ទី ៤ ហៅថាអ្នកងារ (គឺស៊ូទ្រ) ។ ប៉ុន្តែក្នុងកម្ពុជរដ្ឋ លើកលែងមិនឲ្យមានអ្នកងារ តាំងពីក្នុង ព. ស. ២៤៣៥ គ. ស. ១៨៩២ តាំងពីនោះមក ពាក្យថាអ្នកងារក្ដី ព្រៃងារក្ដី ក៏បាត់បន្តិច ៗ ម្ដង ឥឡូវមកគិលប៉ាប្បនេះ ។

២ កម្លោះៈ តាមវចនាស័ព្ទសំដៅយក មនុស្សប្រុសដែលពេញការ, ពេញកំលាំងល្មមមានប្រពន្ធ ៗ តែពាក្យថាៈ កម្លោះ ក្នុងទីនេះសំដៅយកអ្នកងារមួយពួកដែលតែងតែធ្វើការថ្វាយអស់ព្រះវង្ស ឬ ព្រះរាជវង្សានុវង្ស គឺថាជាពួកមនុស្សរបស់ព្រះវង្សទាំងនោះ ក្នុងសម័យមួយណា ។ ៣ មហាតៈ ជាមនុស្សពួកស្នូរៈ ពួកពលរក្សាដំរី សេះ គោ ក៏បី ព្រះរាជទ្រព្យក្នុងសម័យមួយណា ។ ៤ ពលបំរេសៈ តាមក្រសួងប្រែថា ពលដែលប្រោសលែងគឺជាអ្នកងារ ១ ពួក ដែលគេលើកលែងមិនបាច់ធ្វើការឲ្យចៅហ្វាយ ១ បើឲ្យចេញទៅធ្វើការរកស៊ី តាមទំនើងខ្លួនឯងទេដឹង ! ។ ៥ ខ្សោយឃ្លាបលីឃ្លោលៈ សំដៅយកអ្នកកំសត់ទុរគតពិគត្រស្រការ បញ្ចឹមជីវិតនៅក្នុងបន្ទុកអ្នកដទៃផ្លូវជាមនុស្សខ្ញុំគេទាំងពួង ឬមួយនៅក្រៅបន្ទុកអ្នកដទៃ តែជាមនុស្សក្រីក្រលំបាកពោកឃោកឃាំងគ ។

(មានត)

## សេចក្តីសង្ខេបអំពីគោលផ្សេងៗនៃពង្សាវតារខ្មែរ

ហ្លួងនិរៈគ្រូមន្ត្រី ញ៉ុក - ថែម រៀបរៀង

(តមកនឹងលេខ)

អំណើះកាលតមក ក្រុមអហោសិរបស់ព្រះអង្គថ្វាយថ្នាំបំពុលដល់ព្រះចៅគាំខត ទើបទ្រង់ទិវង្គតទៅ ។

លុះព្រះរាជវង្សានុវង្សនឹងសេនាបតី ធ្វើព្រះរាជពិធីបូជាព្រះបរមសពហើយ ទើបសម្តេចព្រះវរជននី បាក់ឲ្យអញ្ជើញទៅព្រះកែវហ្វា មកគ្រងរាជសម្បត្តិជាព្រះមហាក្សត្រ ទ្រង់ព្រះនាម សម្តេចព្រះស្រីធម្មាសោករាជាធិរាជ រាមាធិបតី ។ ក្សត្រអង្គនេះ ទ្រង់គ្រងរាជសម្បត្តិជាវេលា ៣ ឆ្នាំ ទ្រង់ប្រតិបត្តិតាមទសពិធរាជធម៌ទាំង ១០ ប្រការ ។ កាលណោះ ព្រះចៅក្រុងអយុធ្យា សម្តេចព្រះបរមរាជាធិរាជស្តេចលើកទ័ព (ចូលមកស្រុកខ្មែរ) ។ មានទ័ពដំរីនឹងទ័ពសេះលើកមកបោះទ័ពនៅខាងមុខទីក្រុងរបស់ព្រះចៅស្រីធម្មាសោករាជ ។ ដល់គំរប់ ៧ ខែ ទើបព្រះមហាក្សត្រទ្រង់មានព្រះបន្ទូលអង្វរព្រះសង្ឃរាជាគណៈ ២ អង្គគឺ ព្រះធម្មកិច្ចនឹងព្រះសុគន្ធព្រមទាំងឃុនមនោសេនីឃុនមន្តល ឲ្យទៅបរាជាថ្វាយទីក្រុងដល់ព្រះបរមរាជាធិរាជ ។ ចួនជាកាលណោះ ព្រះចៅស្រីធម្មាសោករាជស្តេចទិវង្គតទៅផង ទើបសម្តេចព្រះបរមរាជាធិរាជ ទ្រង់ឲ្យបាក់វែនធ្វើព្រះរាជពិធីបូជាព្រះភ្លើងព្រះបរមសព រួចស្តេចឲ្យកសាងវត្តព្រះជេតុពនប្រគេនព្រះធម្មកិច្ចនៅស្រុកពិស្ណុលោក ហើយទ្រង់ឲ្យកសាងវត្ត

គួប ១ ទៀតប្រគេនព្រះសុគន្ធ ។ ស្តេចទ្រង់ព្រះរាជទានការត្រួតត្រា ព្រះនគរ ហ្លួង ឲ្យព្រះរាជបុត្រព្រះនាម ចៅព្រះរ៉ែត ថៃរក្សា មានព្រះនាមជាព្រះឥន្ទរាជា រួចស្តេចត្រឡប់មកក្រុងអយុធ្យា ព្រមទាំងពួកឈ្លើយសឹកប្រមាណ ៤០,០០០ នាក់ ។

នៅវេលាដែលប្រទេសបរាជ័យចម្បាំងនោះ ព្រះគាំយ៉ាត ទ្រង់គេចទៅជ្រកនៅស្រុកភូមិតនហាក មេស្រុកហៅថាយុទ្ធបាលាជេយ្យ ហើយពួកអ្នកស្រុកនាំគ្នាជួយថែរក្សាទ្រង់ ។ លុះ ១ ឆ្នាំកន្លងទៅ ទើបព្រះគាំ-យ៉ាតគិតធ្វើកលឧបាយ ១ គឺបង្កប់ព្រះខ័ន ១ ក្នុងពាងស្រា ហើយនាំចូលទៅ (ក្នុងព្រះរាជវាំងរបស់ព្រះឥន្ទរាជា) ធ្វើទឹកមុខទំនងជាអ្នកនាំដង្វាយផ្សេង ៗ ចូលទៅថ្វាយស្តេច ។ ព្រះឥន្ទរាជាស្តេចឲ្យបើកពាងនោះមើល ឯមនុស្សដែលលាក់របស់ផ្សេងៗ ចេញមកដល់ព្រះខ័ន ក៏ចាប់កាប់ព្រះឥន្ទរាជាទិវង្គតទៅ ហើយចាប់រឹបយកព្រះមហេសីនិងស្រីព្រះស្នំរបស់ព្រះឥន្ទរាជា ។ ព្រះគាំយ៉ាតឡើងគ្រងរាជសម្បត្តិក្នុងព្រះនគរហ្លួង ទ្រង់ព្រះនាមព្រះរាមាធិបតី ស្រីធម្មិករាជា ។ ព្រះអគ្គមហេសីនាងស្នំ ទ្រង់ព្រះនាម សម្តេចព្រះសង្ឃមិត្រា កើតបានព្រះរាជឱរស ៣ អង្គ: (ព្រះរាជបុត្រ ១ អង្គ) ព្រះនាមព្រះចៅព្រះគាំខត (ព្រះរាជបុត្រី ២ អង្គ) ព្រះនាមនាងព្រះកេសា ១ នាងពុតជូន ១ ។ ទ្រង់យកព្រះស្នំជាតិសៀមម្នាក់ ដែលជាព្រះញាតិខាងព្រះបិតាត្រូវជាព្រះញាតិរបស់ព្រះឥន្ទ-

ពជាផង ទ្រង់តាំងជាព្រះអគ្គមហាសិរីនាងខ្ទើ មានព្រះនាមជា ព្រះឥន្ទ-មិត្រា ។ ឯហេតុទីទី ២ ព្រះនាមទាវទេពគង្គ ជាបុត្រីរបស់ស្ដេចចៅ-មឿងវៃស្ង កើតមានព្រះរាជបុត្រ ១ អង្គទ្រង់ព្រះនាម ហៅព្រះស្រី-រាជ ។ ព្រះស្នំផែលវណ្ណាះអ្នកម៉ែនាងនៃ មានព្រះរាជបុត្រ ៣ អង្គ គឺ: អ្នកនាងប៉ាប ១ ហៅព្រះបណ្ឌិតរាជ ១ ហៅព្រះផាក. ១ ព្រះស្នំម៉ែវរមាលា មានព្រះរាជបុត្រ ១ អង្គ ព្រះនាមអ្នកនាងទេពសាខា ។ ព្រះស្នំម៉ែនាងសុក មានព្រះរាជបុត្រ ១ អង្គគឺហៅព្រះពោធា ។ គឺទេវេកជាជាព្រះរាជបុត្ររបស់ព្រះអគ្គមហាសិរីនាងខ្ទើ (នាងកេសរ) បានសមរសនឹងអ្នកនាងពៅ ជាបុត្ររបស់ម្ចាស់ទ្រង់ព្រះអង្គ នាងទេវះកើតក្នុងឆ្នាំឋោះ(១) កើតបានព្រះរាជបុត្រ ១ អង្គព្រះនាម ហៅព្រះធម្មរាជា ។ ឯអ្នកនាងពៅស្រី នឹងអ្នកនាងកេសរមហាសិរីនាងខ្ទើ ក្រៅជាព្រះញាតិនឹងព្រះស្រីរាជាគាជៃយ អ្នកនាងប៉ាបជាព្រះរាជបុត្រីស្ដេច មានព្រះបុត្រ ១ អង្គព្រះនាមហៅព្រះតាន់ ។ អ្នកនាងទេពសាខា ជាព្រះរាជបុត្រីស្ដេចមានព្រះរាជបុត្រី ១ អង្គព្រះនាមអ្នកនាងទាវផ្គង ។

កាលសម្ដេចព្រះបរមរាជាធិរាជ ស្ដេចចុះទៅតាំងមឿងចតុមុខ(២)

---

(១) ព្រះរាជពង្សាវតារនេះ មិនប្រាប់សករាជទុកឡើយ ពិចារណាតាមបញ្ជាក់សករាជដែលត្រូវនឹងឆ្នាំឋោះនោះ ។ ហើយញ្ញាយ៉ាគរ ផ្ដើមឡើងត្រង់រាជសម្បត្តិកាលពីឆ្នាំ ១៣៩៥ ទើបឃើញថាឆ្នាំឋោះនេះនៅក្នុងឆ្នាំ ១៣៨៧ ឬក្នុងឆ្នាំ១៣៩៩ ។ (២) ក្រុងភ្នំពេញ ។ ញ្ញាយ៉ាគលះទីក្រុងអង្គរហើយមកតាំងក្រុងភ្នំពេញ ។

ទ្រង់បានទទួលដំរីស ១ ជាសិរីសួស្តីនិងកំណាត់ឈើក្រគួ ១ ដែលអណ្តែតមកតាមដងទន្លេលាវ [១] ទើបទ្រង់ឲ្យយកកំណាត់ឈើនេះធ្វើជាសសរគោលសម្រាប់ចងដំរីស ។ រួចសម្តេចព្រះបរមរាជាធិរាជស្តេចលើកទ័ពទៅតាំងកំពង់ទារកា រួចទ្រង់ធ្វើផ្លូវសម្រាប់ទៅច្បាំងលុកលុយទាំង ទ្វារក្រៅ ទ្រង់ខិតខំផ្សាយអានុភាពរបស់ព្រះអង្គ ។ ប៉ុន្តែទ្រង់ទិវង្គតទៅជាវេលាយូរ ក្រោយដែលកងទ័ពបញ្ជាទៅច្បាំងត្រឡប់មកវិញ ។

ទើបព្រះបរមវង្សានុវង្សនិងពួកសេនាបតី នាំគ្នាធ្វើពិធីបូជាព្រះភ្លើងព្រះបរមសពរួចស្រេចហើយ ទើបព្រះរាជបុត្រ ចៅព្រះកាំទត ស្តេចយាងទៅគ្រប់គ្រងរាជសម្បត្តិឯព្រះនគរហ្លួង ទ្រង់ព្រះនាមព្រះនារាយណ៍រាជាធិបតី ។ ព្រះអគ្គមហេសីទ្រង់តាំងជា សម្តេចព្រះភគវតីស្រីព្រះកេសា ទ្រង់សម្ភពព្រះរាជបុត្រ ១ អង្គ ។ សម្តេចព្រះនារាយណ៍ជិតតែទ្រង់បដិបត្តិឧបោសថសីល ហើយតែងទ្រង់ព្រះពស្ត្រស ។ ព្រះមហាក្សត្រអង្គនេះទិវង្គតទៅ ក្រោយដែលបានសោយរាជសម្បត្តិមក ជាវេលាដល់ ២៩ ព្រះវស្សា ។

ក្រោយបូជាព្រះបរមសពហើយព្រះអនុជទាំងពីរអង្គ គឺចៅព្រះស្រីកជាទីនិងចៅព្រះតិអោកជា ទ្រង់តាស់តែងដណ្តើមអំណាចគ្នា ។

---

១ ទន្លេមេគង្គ ។

ចៅព្រះស្រីកដាផាព្រះផង្គាបកជ័យ ហើយស្ដេចទៅតាំងនៅមឿងផាៈ-ៈយាន ។ ចៅព្រះគិរេសកផាះឡឹងត្រឹកជ្យទៅន គរហ្លួង ទ្រង់ព្រះនាមសម្ដេចព្រះស្រីសោរិទយ ។ ចៅព្រះស្រីកដាលើកទ័ពមកច្បាំងនឹងព្រះអនុជស្រីសូរិទយ ។ ចាប់ព្រះអង្គបាន ហើយធ្វើគត់ទៅនៅពិបខ់ញា.លាគតារ ។

កាលនៅគ្នឹកផុលសម្បត្តិនោះ សម្ដេចព្រះស្រីសោរិទយមិនបាននុកព្រះទ័យចំពោះព្រះធម្មកជាទេ ទ្រង់មានបំណងនឹងឲ្យធ្វើគត់ទៅ ។ ទើបព្រះរាជអយ្យការនាងកេសកបានប្រាប់រឿង ក៏លបលួចឲ្យដំណាំងស៊ំ-ងាត់ទៅដល់ចៅព្រះយាព្រះធម្មកជា ។ ក៏ទ្រង់គេចរត់ទៅរោកព្រះអគ្គពួននៅស្រុកត្រនេអាក ហើយទ្រង់ប្រមូលពួកពលបានចំនួនច្រើន ទើបទ្រង់ជាមេទ័ពលើកមកច្បាំងនឹងព្រះស្រីសោរិទយ ។ គតាំងមិនបាន ក៏ស្ដេចរត់ទៅស្រុកចង្ក្រណាក់ ។ ព្រះអគ្គពួនធ្វើជាកងទ័ពមានពលជាចំ-នួនច្រើន ហើយស្ដេចត្រឡប់មកច្បាំងតតាំងនឹងចៅព្រះយាព្រះធម្មកជា ។ ចៅព្រះយាព្រះធម្មកជាស្ដេចគេចរត់ទៅស្រុកជាលីម . នៅទាងដើងក្ដ-រុង(១) តាំងចំងៈបំបោរបណ្ដាកស្រួ ទៅស្រុកទឹងនៅក្ងមខាងកើតទាំងប៉ុន្មាន ហើយលើកទ័ពមកវាយយកទីក្រុងបាន ។ ព្រះស្រីសូរិទយ៍ស្ដេច

---

១ ក្លុងតៅខាងជើងភ្នំដងរែក ខាងកើតកោរាជ ។

គេពាត់ទៅ (តំបន់) ច្រាំបីដុំ[1] មឿនលង្វែក រួចទ្រង់មានព្រះរាជបង្គាប់ មន្ត្រីម្នាក់ឈ្មោះ ចៅជ័យមន្ត្រី ឲ្យលើកទ័ពចេញទៅជួបជុំគ្នា នៅត្រពាំង លង្កា[2] ។ នៅពេលស្តេចរេះទៅដល់ម ព្រះធម្មរាជាទ្រង់តាំងកិច្ច ការពារការជាមួយនឹងមន្ត្រីម្នាក់ ។ កាលទ្រង់យកបានព្រះខគ្គហើយ ហើយក៏ទ្រង់ជូនដំណឹងទៅដល់មេកួយនោះ ដើម្បីសុំកម្លាំងកងទ័ព អំពីត្បូងឃ្មុំ បម្រាប់ជួយទ្រង់ច្បាំងតទល់នឹងព្រះស្រីសូរិយោពណ៌ឯលង្វែក ។ គាំពំអំពីកងទ័ពកួយបានលើកទៅជួយច្បាំង ចៅព្រះយាព្រះធម្មរាជាក៏ យាត្រាទ័ពទៅច្បាំងតទល់នឹងព្រះស្រីសូរិយោពណ៌ ៗ ទប់ទល់មិនបានក៏បរា-ជ័យតែទៅរោលព្រះរាជបរិពារ ៗ គ្រានោះ ពួកទាហានរបស់ព្រះធម្ម-រាជាក៏ដោយចាប់រាជបរិពារ នឹងពួកព្រះជាយារបស់ព្រះសូរិយោពណ៌បានជា ចំនួនច្រើន ។ ចៅជ័យមន្ត្រីក៏នាំអ្នកនាងព្រះកេសា អគ្គមហេសីទៅ ថ្វាយព្រះរាជបុណ្យកម្មាធិបតី ដែលទ្រង់តែងចេញទៅពួននៅស្រុក ពោធិ៍សាត់[3] ; ឯព្រះស្រីសូរិយោពណ៌ស្តេចគេចរត់ហួតទៅដល់អយុធ្យា ។ ចៅព្រះរាជបុត្រអ្នកនាងព្រះកេសា ក៏ប្រកាសព្រះអង្គជាក្សត្រនៅ ពោធិ៍សាត់ព្រះធម្មរាជាក៏លើកទ័ពចេញទៅច្បាំងនឹងស្តេចថ្មី ។ ចៅព្រះ (បុត្ររបស់ព្រះកេសា) ចេញមកឃាត់នៅតាមមុខទ្រង់ ៗ ចៅព្រះ

---

១ ច្រាំបីដុំៈ នៅលើដែនខ្មែរ ខាងលិចលង្វែក ២ សព្វថ្ងៃ ជ្រោយចង្វារ នៅទល់មុខក្រុង ភ្នំពេញសព្វថ្ងៃ ។ ៣ ស្រុកពោធិ៍សាត់ នៅខាងក្នុងខេត្តបរ ។

ផម្ពុជាយពាក់ថា ស្ត្រីរបស់ទ្រង់មានផ្ទៃពោះ ទើបថយទ័ពហូត មកដល់ស្រុកបរិបូណ៌(១) ហើយពួកមកនាការៀង(២) ឈ្មោះយុទ្ធរុធ ក៏នាំទ័ពទៅវាយក្រុងការពារទៅពញ៉ា នៅបឿងពាន់សាក់នោះឯង ។

---

១ បរិបូណ៌ នៅខាងត្បូងទន្លេសាប ។ ២ ការៀងជាពួកមនុស្សព្រៃ ១ ពួក ។

# តារាងប្រវត្តិរាជត្រកូល

## ស្រង់ចេញពីរាជនិពន្ធ ដែលព្រះបាទអង្គអេងថ្វាយដល់ព្រះចៅក្រុងស្យាមកាលពីឆ្នាំ ១៧៩៦.



# អធិប្បាយសុភាសិតខ្មែរ

## ឃុនឧត្តមប្រីជា ចាប ពិន រៀបរៀង

(តមក)

### ៩៥-បម្រើឲ្យមើលចិត្ត បើមា

គំនិត សូមឲ្យទ្រព្យ

ពាក្យនេះបុរាណលោកប្រើថា

ប្រដៅឲ្យយើងចេះពិនិត្យ | ឃើញមនុស្សល្អពិតសឹងសង្គ្រោះ ។
គឺឲ្យសង្កេតមនុស្សបម្រើ | បើឃើញគ្រាន់បើឥតមានទោះ
សូមឲ្យមេត្តាជួយសង្គ្រោះ | ឲ្យមានកេរ្តិ៍ឈ្មោះឬឲ្យទ្រព្យ ។
កុំឲ្យសង្គ្រោះដោយពាយ៉ាភាយ | ក្រែងដល់ទៅនាយមិនកតញ្ញូ
ព្រោះមានមនុស្សខ្លះថ្ងៃមុនគាប់ ; | ថ្ងៃក្រោយគេត្រឡប់ឲ្យទោសវិញ ។

### ៩៦-បាតដៃ ជាខ្នងដៃ

ពាក្យនេះជាពាក្យបន្ទោសគ្នា

កន្លងពេលដែលមានមនុស្សសោក | ច្រឡាស់សំដីខ្លួនមិនទៀង ។
ម្តងថាដូច្នេះម្តងដូច្នោះ | មិនឈរត្រង់ណាឲ្យជាក់ជាង
ជាពាក្យនិយាយដោយលំអៀង | បញ្ចៀងចង្អុលអត្ថស្រយ៉ ។
បើអ្នកដែលស្តាប់មិនសន្តោស | តែងស្តីបន្ទោសថាចង្រៃ
ម្តេចក៏បាតដៃជាខ្នងដៃ | ដូចនេះហៅដែលពាលក្នុងតាតិកា ។

## ៤៧-ធ្វើបាបមិនឆ្អាបមាត់

ពាក្យនេះជាពាក្យទាក់បណ្ដោយ

ក្នុងពេលធ្វើការអ្វីផ្ទួស ជាយ　　　នាំឲ្យរកានចិត្តខ្ពង់ខ្ពស់
ដូចយ៉ាងបានធ្វើអំពើណា　　　ដែលនាំគេគ្មានឲ្យរវល់
លុះបាក់លំបិនជាអំពល់　　　នាំនឹកបានទាល់ប្រយោជន៍ទេ ៗ
ដូចមានគេពឹងឲ្យធ្វើការ　　　ដែលមានខ្លឹមសារការនឹងគេ
ខាងអ្នកដែលធ្វើអត់បានទេ　　　បានច្រើនតែគេលើសប្រមាណ ៗ
ឬដូចអ្នកណាចិត្តកាព្រះ　　　តក់ម៉ក់សម្លាប់សត្វតិរច្ឆាន
ឲ្យគេវេទនាខកខាន　　　ពុំបានបរិភោគចូលក្នុងមាត់ ៗ
យ៉ាងនេះជាដើមគួរបានប្រាប　　　ហៅថា "ធ្វើបាបមិនឆ្អាបមាត់"
ជាពាក្យប្រាជ្ញចាស់លោកហាមឃាត់　　　ឲ្យយើងចាំស្មាគប្រយ័ត្នខ្លួន ៗ

## ៤៨-បីចាប់ថៃនាំនាំឲ្យគង់ផល

ពាក្យនេះអ្នកប្រាជ្ញប្រាប់អានិសង្ស

ជាគ្រឿងរក្សាទ្រព្យឲ្យគង់　　　កុំឲ្យលិចលង់ខូចរបស់ ៗ
ឯការបីបាច់ថែរក្សា　　　ថែទាំទ្រព្យសព្វទាំងអស់
អ្នកណាប្រព្រឹត្តឥតមានខ្វះ　　　របស់ទាំងគង់មិនបង់បាត់ ៗ
ហេតុនេះអ្នកប្រាជ្ញលោកទូន្មាន　　　ឲ្យអស់យើងបានចំប្រយ័ត្ន
ថែទាំទ្រព្យធនកុំឲ្យខ្ចាត់　　　ទើបបានសម្បត្តិទ្រព្យគង់នៅ ៗ

## ៩៩. ពោះសន្ធប់លង់ក្អម

ពាក្យពោះសន្ធប់លង់ក្អម

ដឹកគិតការត្បៀតព្រាលអ្នកធំ    ទៅទំព្ពាប់ផ្ទុនឯអ្នកតូច ។
បើការនោះស្រួលក៏ត្រាន់បើ    តែបើការនោះនៅជារខូច
ដោយហេតុព្រាលធំទៅកតូច    ពាលខូចតែងត្រូវបះគ្នាសធំ ។
ថា មេបក់ធ្វើយ៉ាងដូចោះ    ទៅៈពោះសន្ធប់លង់ក្អម
កំពើយ៉ាងនេះមិនគួរសម    អ្នកធំនេះមុខមេបមិនផ្អាប់ ។
អស់កិច្ចតាំងពួងប្រើនអសារ    ខូចការលិចលង់បង់អភ័ព
ពីព្រោះតែល្ងង់មិនចេះផ្អាប់    ឲ្យជាប់និស្ស័យទៅអ្នកធំ ។

## ១០០ ប្រមាធព្រៀងលាង

តែងបានក្តីទុក្ខ

សុភាសិតនេះជាទុកទេ

គួនមិនឲ្យមនុស្សប្រមាថ    ផល់ញាតិសន្តានឥតប្រណី ។
ពាក្យថាប្រមាថក្នុងមាតិកា    ប្រែថា "ប្រាំហាសចេ្មសស្នាតើ"
ប៉ុន្តែខ្មែរយើងច្រើនស្រដី    ថាកាចអប្រិយព្រហើនក្លាំង ។
ប្រុជាម៉ោៈនាំយាវយជាក់ប្រែ    បន្ទឹបន្ទួបជាខ្លាំង
សក្រូនទើងគ្នាតិតប្រឆាំង    ខ្លាំង ។ ឥតកោតអស់ញាតិផង ។

អ្នកដែលប្រមាទមិនបានសុខ  ច្រើនតែកើតទុក្ខពេកកន្លង
ទាំងក្នុងលោកនេះលោកនាយហោង  សឹងវេទនាជាអនេក ។

## ១០១- ប្រហែសធាត់ ប្រយ័ត្នគង់

សុភាសិតនេះលោកហាមឃាត់
ឲ្យយើងចេះថែចេះប្រយ័ត្ន  វិជ្ជាសម្បត្តិទាំងតូចធំ ។
មិនឲ្យប្រហែសភ្លេចស្មារតី  វិជ្ជាទ្រព្យអ្វីត្រូវរៀបចំ
ត្រូវចេះរំលឹកចេះសន្សំ  ចេះរៀនចេះចាំកុំខានឡើយ ។
បើភ្លេចប្រហែសមុខជាខាត  វិជ្ជាសម្បត្តិដែលបានហើយ
កើតស្តាយក្នុងចិត្តឥតមានស្បើយ  នេះហើយទើបប្រាជ្ញលោកពោលថា ។
«ប្រហែសធាត់ប្រយ័ត្នគង់»  គួរយើងទទួលដោយប្រាជ្ញា
ទាំងហើយត្រូវនាំគ្នាស្វាហាប់  ប្រយ័ត្នណាស់ណាតាមលោកប្រាប់ ។

## ១០២- ប្រាជ្ញមិនស្មើព្រប បម្រើនធំ
## ស៊ីត្រពៀតកាខូប មិនស្មើឡេមឡឺម

ពាក្យនេះមានពីបុរាណនាយ
ចាស់ៗខ្មែរយើងតែងនិយាយ  អភិប្រាយប្រាប់គ្នាជារឿយៗ ។
ក្នុងពេលដែលមានអ្នកចេះដឹង  បានប្រឹងធ្វើការយ៉ាងហត់នឿយ
បម្រើចៅហ្វាយនាយរឿយៗ  មិនគិតហត់នឿយចន្លិចសោះ ។

ប៉ុន្តែច្បាស់ខាងដៃកំប្រឹង / មិនដឹងខាងប្រាប់ចៅហ្វាយនោះ
ចៅហ្វាយតែងក្រួចជួយសង្គ្រោះ / ពីព្រោះខ្លួនឯងមិនចេះគប់ ។
អ្នកខ្វះមិនចេះប៉ុន្មានទេ / តែគេប្រសប់ខាងរៀបឡប
ចៅហ្វាយសង្គ្រោះព្រោះចេះប្រាប់ / ចេះឧបាយកលទើបគេគិត ។
ព្រោះហេតុដូច្នោះទើបបាកណា / លោកបានចង់ជាសុភាសិត
ដើម្បីឲ្យយើងបានគំនិត / ចេះគិតអែបអបឧបយកសុខ ។

## ៣០៣—ប្រើនៅជាត្បូងចិញ្ចៀន ក្រវេង ក្រវៀនជាមៀនកាំបិត

ពាក្យនេះលោកពោលចំពោះមនុស្ស

ទទួលបម្រើធ្វើឲ្យខុស / កំហុសកន្លះពេលដែលប្រើទៅ ។
ដូចប្រើឲ្យទៅធ្វើការអ្វី / ឬឲ្យទៅស្តីការកក់ក្តៅ
ហើយអ្នកទទួលបម្រើទៅ / ធ្វើការមិនត្រូវតាមបង្គាប់ ។
ការនោះមិនបាច់ពោលឲ្យចំ / ស្រេចតែលំនាំនៃអ្នកប្រាប់
ហើយអ្នកបម្រើភ្ញាក់ចំណាប់ / មិនដូចបង្គាប់អ្នកប្រើទៅ ។
អ្នកប្រើប្រែចិត្តញញួរដូចពោលមក / ទើបប្រាជ្ញលោកយកមកប្រដៅ
ឲ្យយើងចេះប្រើមនុស្សឲ្យទៅ / ដោយអោយពិនិត្យសិនសមជាក់ ។

(មានត)

# អរិយសច្ចជាពុទ្ធភាសិត

## ព្រះអាចារ្យ ប៉ាង-ខាត់ ប្រែរៀបរៀង (តចកនំងប់)

អរិយសច្ចបែកជា ៤ ប្រការ និងបែកចេញទៅដោយសង្ខេប

ម្នាលភិក្ខុទាំងឡាយ! អរិយសច្ចទាំងឡាយនេះមាន ៤ ប្រការ ។ អរិយសច្ចទាំងឡាយ ៤ ប្រការតើអ្វីខ្លះ? អរិយសច្ចទាំងឡាយ ៤ ប្រការគឺៈ ទុក្ខជាសេចក្ដីពិតដ៏ប្រសើរ ១ ហេតុប្រជុំកើតឡើងនៃទុក្ខជាសេចក្ដីពិតដ៏ប្រសើរ ១ ធម៌ជាគ្រឿងរំលត់ទុក្ខជាសេចក្ដីពិតដ៏ប្រសើរ ១ សេចក្ដីប្រតិបត្តិជាដំណើរទៅកាន់ទីរំលត់ទុក្ខជាសេចក្ដីពិតដ៏ប្រសើរ ១ ។

ម្នាលភិក្ខុទាំងឡាយ! សេចក្ដីពិតដ៏ប្រសើរគឺទុក្ខ តើដូចម្ដេច? ពាក្យឆ្លើយ គឺខន្ធជាគ្រឿងប្រកាន់ ៥ យ៉ាង ។ ខន្ធជាគ្រឿងប្រកាន់ ៥ យ៉ាងតើអ្វីខ្លះ? ខន្ធជាគ្រឿងប្រកាន់ ៥ យ៉ាងគឺៈ ខន្ធជាគ្រឿងប្រកាន់គឺរូប ១ ខន្ធជាគ្រឿងប្រកាន់គឺវេទនា ១ ខន្ធជាគ្រឿងប្រកាន់គឺសញ្ញា ១ ខន្ធជាគ្រឿងប្រកាន់គឺសង្ខារ ១ ខន្ធជាគ្រឿងប្រកាន់គឺវិញ្ញាណ ១ ម្នាលភិក្ខុទាំងឡាយ! នេះតថាគតហៅថាសេចក្ដីពិតដ៏ប្រសើរ គឺទុក្ខ ។

ម្នាលភិក្ខុទាំងឡាយ! សេចក្ដីពិតដ៏ប្រសើរគឺហេតុប្រជុំកើតឡើងនៃទុក្ខ តើដូចម្ដេច? គឺតណ្ហាឯណាមួយជាគ្រឿងនាំទៅកាន់ភពថ្មី ប្រកបដោយរាគៈ ប្រព្រឹត្តទៅដោយអំណាចសេចក្ដីត្រេកត្រអាល និងកិរិយាចូលចិត្តត្រេកត្រអាលទៅក្នុងអារម្មណ៍នោះ ៗ ។ តណ្ហានោះដូចម្ដេចខ្លះ? តណ្ហានោះគឺៈ កាមតណ្ហា ១ ភវតណ្ហា ១ វិភវតណ្ហា ១ ។ ម្នាល

ភិក្ខុទាំងឡាយ! នេះតថាគតហៅថាសេចក្ដីពិតដ៏ប្រសើរ គឺហេតុប្រជុំកើតឡើងនៃទុក្ខ ។

ម្នាលភិក្ខុទាំងឡាយ! សេចក្ដីពិតដ៏ប្រសើរគឺធម៌ជាគ្រឿងរំលត់នៃទុក្ខ តើដូចម្ដេច? សេចក្ដីរំលត់ព្រោះកិរិយាអស់ទៅនៃតណ្ហា ដោយមិនសេសសល់ កិរិយាលះលែង កិរិយាលះបង់ កិរិយារួចស្រឡះ កិរិយាមិនមានអាល័យ នូវតណ្ហានោះៗ ឯង ម្នាលភិក្ខុទាំងឡាយ! នេះតថាគតហៅថាសេចក្ដីពិតដ៏ប្រសើរ គឺធម៌ជាគ្រឿងរំលត់ទុក្ខ ។

ម្នាលភិក្ខុទាំងឡាយ! សេចក្ដីពិតដ៏ប្រសើរគឺសេចក្ដីប្រតិបត្តិជាដំណើរទៅកាន់ទីរំលត់ទុក្ខ តើដូចម្ដេច? មគ្គដ៏ប្រសើរមានអង្គ ៨ ប្រការនេះឯង, ដូចម្ដេចខ្លះ? គឺសេចក្ដីយល់ត្រូវ ១ សេចក្ដីត្រិះរិះត្រូវ ១ វាចាត្រូវ ១ ការងារត្រូវ ១, ចិញ្ចឹមជីវិតត្រូវ ១, សេចក្ដីព្យាយាមត្រូវ ១ ស្មារតីត្រូវ ១, សេចក្ដីតាំងចិត្តត្រូវ ១; ម្នាលភិក្ខុទាំងឡាយ! នេះតថាគតហៅថាសេចក្ដីពិតដ៏ប្រសើរ គឺសេចក្ដីប្រតិបត្តិជាដំណើរទៅកាន់ទីរំលត់ទុក្ខ ។

ម្នាលភិក្ខុទាំងឡាយ! នេះហៅថាអរិយសច្ច ៤ ប្រការ ។ ម្នាលភិក្ខុទាំងឡាយ! អ្នកទាំងឡាយ គប្បីព្យាយាមដើម្បីឲ្យដឹងច្បាស់ថា: "នេះទុក្ខ នេះហេតុប្រជុំកើតឡើងនៃទុក្ខ នេះធម៌ជាគ្រឿងរំលត់ទុក្ខ នេះសេចក្ដីប្រតិបត្តិជាដំណើរទៅកាន់ទីរំលត់ទុក្ខ តែប៉ុណ្ណោះ ។

មហាវារៈ សំ. ១៩ - ៥៣៤ - ៥៤៨

# ទ្រង់រៀងលំដាប់អរិយសច្ច ស្លាប់ក្រឡា

ម្នាលភិក្ខុ អ្នកមិនទ្រទ្រង់នូវអរិយសច្ចទាំង៤ប្រការ ដែលតថាគតសំដែងទុកហើយឬ? ..... បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គបានទ្រទ្រង់នូវអរិយសច្ចទាំង៤ប្រការ ដែលទ្រង់សំដែងទុកហើយ

ម្នាលភិក្ខុ! អ្នកចាំទុកនូវអរិយសច្ចទាំង៤ប្រការ ដែលតថាគតបានសំដែងទុកហើយយ៉ាងណា? បពិត្រព្រះអង្គដ៏ចំរើន! ខ្ញុំព្រះអង្គចាំទុកថា: ទុក្ខអរិយសច្ច ព្រះភគវន្តទ្រង់សំដែងទុកជាបឋម ទុក្ខសមុទយអរិយសច្ច ជាទីពីរ ទុក្ខនិរោធអរិយសច្ច ជាទីបី ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច ជាទីបួន បពិត្រព្រះអង្គដ៏ចំរើន! ខ្ញុំព្រះអង្គបានចាំទុកថាអរិយសច្ចទាំង៤ប្រការដែលទ្រង់សំដែងទុកហើយយ៉ាងហ្នឹងឯង។

សាធុ! សាធុ! ត្រូវហើយ! ត្រូវហើយ! ម្នាលភិក្ខុ អ្នកបានចាំទុកនូវអរិយសច្ចទាំង៤ប្រការ ដែលតថាគតសំដែងទុកហើយ ត្រឹមត្រូវមែន ម្នាលភិក្ខុ! តថាគតសំដែងនូវទុក្ខអរិយសច្ចទុកជាបឋម អ្នកក៏បានចាំនូវទុក្ខអរិយសច្ចនោះមែន តថាគតសំដែងទុក្ខសមុទយអរិយសច្ចទុកជាទីពីរ អ្នកបានចាំនូវទុក្ខសមុទយអរិយសច្ចនោះមែន តថាគតសំដែងនូវទុក្ខនិរោធអរិយសច្ចទុកជាទីបី អ្នកក៏បានចាំនូវនិរោធអរិយសច្ចនោះមែន តថាគតសំដែងនូវទុក្ខនិរោធគាមិនីបដិបទាទុកជាទីបួន អ្នកក៏បានចាំនូវទុក្ខនិរោធ-

ការមិនបដិបត្តិតាមអរិយសច្ចដូច្នោះមែន ម្នាលភិក្ខុ! អ្នកត្រូវចាំទុកនូវអរិយ-សច្ចទាំងឡាយ ៤ ប្រការ ដែលតថាគតសំដែងទុកហើយយ៉ាងនេះចុះ ។

អ្នកណាមួយរៀនលំដាប់ថ្មីទៀត មិនត្រូវតែនូវធម៌ទេ

ម្នាលភិក្ខុ! បុគ្គលឯណាមួយ ទោះជាសមណក្តី ឬជាព្រាហ្មណ៍ក្តី មកពោលយ៉ាងនេះថា "ទុក្ខអរិយសច្ចដែលព្រះសមណគោតមសំដែងទុកជាទី ១ ទុក្ខសមុទយអរិយសច្ចជាទីពីរ ទុក្ខនិរោធអរិយសច្ចជាទី ៣ ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ចជាទីបួន នេះមិនត្រឹមត្រូវទេ ខ្ញុំបញ្ញត្តអរិយសច្ចផ្សេង ៗ ទៅទៀត ដូច្នេះ ពាក្យនេះមិនត្រូវតាមគន្លងធម៌ទេ ។ ម្នាលភិក្ខុ! អ្នកចូរចងចាំទុកនូវអរិយសច្ចទាំងឡាយ ៤ ប្រការ ដែលតថាគតសំដែងយ៉ាងនេះចុះ ។

មហាវារៈ សំ. ១៩ - ៥៩៦ - ១៦៩០ - ៣

## នាទីឬកិច្ចរបស់អរិយសច្ចមានតែបួនបែប

ម្នាលភិក្ខុទាំងឡាយ! អរិយសច្ចទាំងឡាយនេះមាន៤ ប្រការ ដូចម្ដេចខ្លះ? ទុក្ខជាអរិយសច្ច ១ ហេតុប្រជុំកើតឡើងនៃទុក្ខជាអរិយសច្ច ១ ធម៌ជាគ្រឿងរលត់នៃទុក្ខជាអរិយសច្ច ១ សេចក្ដីប្រតិបត្តិជាដំណើរទៅកាន់ទីរលត់ទុក្ខ ជាអរិយសច្ច ១ ។ ម្នាលភិក្ខុទាំងឡាយ! នេះឯងហៅថាអរិយសច្ច៤ ។ ម្នាលភិក្ខុទាំងឡាយ! ក្នុងអរិយសច្ចទាំងឡាយ ៤ ប្រការនោះ អរិយសច្ចដែលអ្នកត្រូវកំណត់ដឹងក៏មាន អរិយសច្ច ដែលអ្នកត្រូវលះ

បង់ក៏មាន អរិយសច្ចដែលអ្នកត្រូវធ្វើឲ្យជាក់ច្បាស់ក៏មាន និងអរិយសច្ចដែលអ្នកត្រូវចំរើនឲ្យច្រើនក៏មាន ។

ម្នាលភិក្ខុទាំងឡាយ! អរិយសច្ចដែលអ្នកគប្បីកំណត់ដឹង តើដូចម្តេច ម្នាលភិក្ខុទាំងឡាយ! ទុក្ខអរិយសច្ចអ្នកត្រូវកំណត់ដឹង ទុក្ខសមុទយអរិយសច្ច អ្នកត្រូវលះបង់ចោល ទុក្ខនិរោធអរិយសច្ច អ្នកត្រូវធ្វើឲ្យជាក់ច្បាស់ ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច អ្នកត្រូវភាវនាធ្វើឲ្យចំរើនឡើង ។

មហាវារៈ សំ. ១៩ - ៥៤៦ - ១៣ ៩

អរិយសច្ច ៤ មានបរិវដ្ត ៣ មានអាការៈ ១២

១- ម្នាលភិក្ខុទាំងឡាយ! ភ្នែកតថាគតកើតហើយ ញាណតថាគតកើតហើយ ប្រាជ្ញាតថាគតកើតហើយ វិជ្ជាតថាគតកើតហើយ ពន្លឺតថាគតកើតហើយ ក្នុងធម៌ដែលតថាគតមិនដែលបានឮបានស្តាប់ពីក្នុងកាលមុនថា " ១ នេះសេចក្តីពិតដ៏ប្រសើរគឺទុក្ខ ២ សេចក្តីពិតដ៏ប្រសើរគឺទុក្ខនេះ បុគ្គលគួរកំណត់ដឹង ៣ សេចក្តីពិតដ៏ប្រសើរគឺទុក្ខនេះ តថាគតកំណត់ដឹងរួចហើយ " ។

២- ម្នាលភិក្ខុទាំងឡាយ! ភ្នែកតថាគតកើតហើយ ញាណតថាគតកើតហើយ ប្រាជ្ញាតថាគតកើតហើយ វិជ្ជាតថាគតកើតហើយ ពន្លឺតថាគតកើតហើយ ក្នុងធម៌ដែលតថាគតមិនដែលបានឮ មិនដែល

បានស្តាប់មកក្នុងកាលមុនថា "១ នេះសេចក្តីពិតដ៏ប្រសើរគឺហេតុប្រជុំកើតឡើងនៃទុក្ខ ២ សេចក្តីពិតដ៏ប្រសើរគឺហេតុប្រជុំកើតឡើងនៃទុក្ខនេះបុគ្គលគប្បីលះបង់ចោល ៣ សេចក្តីពិតដ៏ប្រសើរគឺហេតុប្រជុំកើតឡើងនៃទុក្ខនេះឯង តថាគតលះបង់ចោលហើយ" ។

៣- ម្នាលភិក្ខុទាំងឡាយ ! ភ្នែកតថាគតកើតហើយ ញាណតថាគតកើតហើយ ប្រាជ្ញាតថាគតកើតហើយ វិជ្ជាតថាគតកើតហើយ ពន្លឺតថាគតកើតហើយ ក្នុងធម៌ដែលតថាគតមិនដែលបានឮបានស្តាប់មកក្នុងកាលមុនថា "១-នេះសេចក្តីពិតដ៏ប្រសើរ គឺធម៌ជាគ្រឿងរំលត់នៃទុក្ខ ២-សេចក្តីពិតដ៏ប្រសើរគឺធម៌ជាគ្រឿងរំលត់នៃទុក្ខនេះ បុគ្គលគប្បីធ្វើឲ្យជាក់ច្បាស់ ៣-សេចក្តីពិតដ៏ប្រសើរគឺធម៌ជាគ្រឿងរំលត់នៃទុក្ខនេះឯង តថាគតបានធ្វើឲ្យជាក់ច្បាស់ហើយ" ។

៤- ម្នាលភិក្ខុទាំងឡាយ ! ភ្នែកតថាគតកើតហើយ ញាណតថាគតកើតហើយ ប្រាជ្ញាតថាគតកើតហើយ វិជ្ជាតថាគតកើតហើយ ពន្លឺតថាគតកើតហើយ ក្នុងធម៌ដែលតថាគតមិនដែលបានឮបានស្តាប់មកក្នុងកាលមុនថា "១- នេះសេចក្តីពិតដ៏ប្រសើរ គឺសេចក្តីប្រតិបត្តិជាដំណើរទៅកាន់ទីរំលត់ទុក្ខ ២- សេចក្តីពិតដ៏ប្រសើរ គឺសេចក្តីប្រតិបត្តិជាដំណើរទៅកាន់ទីរំលត់ទុក្ខនេះ បុគ្គលគប្បីធ្វើឲ្យច្រើនឡើង ៣ សេចក្តីពិត

ដ៏ប្រសើរ គឺសេចក្ដីប្រតិបត្តិជាដំណើរទៅកាន់ទីរលត់នេះឯង តថាគតបានការនោះច្រើនរូបហើយ" ។

ម្នាលភិក្ខុទាំងឡាយ! ដរាបណា ញាណទស្សនៈ គឺប្រាជ្ញាដឹងឃើញតាមពិតនៃតថាគត ក្នុងអរិយសច្ចទាំងឡាយ ៤ ប្រការ ដ៏មានបរិវដ្ដ ៣ មានអាការ ១២ ដូច្នេះ នៅមិនទាន់បរិសុទ្ធផូរផង់ល្អទេ ដរាបនោះ តថាគតក៏មិនទាន់បាននាមបញ្ញត្តិថា ត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណទេ............... ។

ម្នាលភិក្ខុទាំងឡាយ ? លុះកាលណា ញាណទស្សនៈ គឺប្រាជ្ញាដឹងឃើញតាមពិតនៃតថាគត ក្នុងអរិយសច្ចទាំងឡាយ ៤ ប្រការ ដ៏មានបរិវដ្ដ ៣ មានអាការ ១២ ដូច្នេះ បរិសុទ្ធផូរផង់ល្អហើយ ក្នុងកាលណោះ ទើបតថាគតបាននាមបញ្ញត្តិថា ត្រាស់ដឹងនូវអនុត្តរិយសម្មាសម្ពោធិញ្ញាណ....... ។

, មហាវារៈ សំ. ១៩ : ៥២៩ - ១៦៦៦

## ពាក្យវេវិចនៈ ឬពាក្យជំនួសឈ្មោះអរិយសច្ច

ម្នាលភិក្ខុទាំងឡាយ? ចុះធម៌ទាំងឡាយ ដែលគប្បីកំណត់ដឹងដោយប្រាជ្ញាដ៏ឧត្ដម តើដូចម្ដេច? ត្រូវឆ្លើយថា បានដល់ឧបាទានក្ខន្ធ (គំនរនៃសេចក្ដីប្រកាន់មាំ) ទាំង ៥ គឺ រូបូបាទានក្ខន្ធ ១ វេទនូបាទានក្ខន្ធ ១ សញ្ញូបាទានក្ខន្ធ ១ សង្ខារូបាទានក្ខន្ធ ១ វិញ្ញាណូបាទានក្ខន្ធ ១ នេះឯង

ដែលជាធម៌គប្បីកំណត់ដឹងដោយប្រាជ្ញាដ៏ឧត្តម; ម្នាលភិក្ខុទាំងឡាយ ! ចុះធម៌ទាំងឡាយដែលគប្បីលះបង់ដោយប្រាជ្ញាដ៏ឧត្តម តើដូចម្តេច? (គ្រូឆ្លើយថា:) អវិជ្ជានឹងភវតណ្ហានេះឯង ជាធម៌ត្រូវលះបង់ដោយប្រាជ្ញាដ៏ឧត្តម ។ ម្នាលភិក្ខុទាំងឡាយ ចុះធម៌ទាំងឡាយ ដែលគប្បីចំរើនដោយប្រាជ្ញាដ៏ឧត្តមតើដូចម្តេច? (គ្រូឆ្លើយថា:) សមថនឹងវិបស្សនា, សមថនឹងវិបស្សនានេះឯង ជាធម៌ត្រូវចំរើនដោយប្រាជ្ញាដ៏ឧត្តម ។ ម្នាលភិក្ខុទាំងឡាយ ចុះធម៌ទាំងឡាយដែលគប្បីធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញាដ៏ឧត្តម តើដូចម្តេច? (គ្រូឆ្លើយថា:) វិជ្ជានឹងវិមុត្តិ, វិជ្ជានឹងវិមុត្តិនេះឯង ជាធម៌ត្រូវធ្វើឲ្យជាក់ច្បាស់ដោយប្រាជ្ញាដ៏ឧត្តម ។

ម. ឧប. សឡាយនវគ្គ, សឡាយនវិភង្គ. ២៨-៣៤១-៣០៤

សេចក្តីពន្យល់: ឧបាទានក្ខន្ធ បានដល់ទុក្ខសច្ច, អវិជ្ជានឹងតណ្ហា បានដល់សមុទយសច្ច, វិជ្ជាគឺការចេះដឹង វិមុត្តិសេចក្តីរួចស្រឡះ បានដល់និរោធសច្ច, សមថ គឺឧបាយស្ងប់ចិត្តជាសមាធិ នឹងវិបស្សនា គឺឧបាយឲ្យឃើញច្បាស់ក្នុងធម៌ទាំងពួងបានដល់មគ្គសច្ច ហេតុនេះទើបហៅថាបវត្តន:នៃចតុរារិយសច្ច ក្នុងទីនេះ ។

អវសាន: